ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពជាតិ
# ស្ដីពី
# គំនិតផ្ដួចផ្ដើមសម្រាប់កាត់បន្ថយភាព
# អត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា
# (២០១៦-២០២៥)


រៀបចំដោយ

ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានការពិគ្រោះយោបល់

ជាមួយក្រុមការងារបច្ចេកទេសចម្រុះស្ដីពីគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ



រាជធានីភ្នំពេញ ខែមីនា ឆ្នាំ ២០១៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពជាតិ
# ស្តីពី
# គំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាព
# អត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា
# (២០១៦-២០២៥)




រៀបចំដោយ

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានការពិគ្រោះយោបល់

ជាមួយក្រុមការងារបច្ចេកទេសចម្រុះស្តីពីគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

រាជធានីភ្នំពេញ ខែមីនា ឆ្នាំ ២០១៦

# អារម្ភកថា

រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានប្តេជ្ញាសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ដោយចីរភាពក្នុងការ "**បញ្ចប់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀង និងកែលម្អអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មដែលមាននិរន្តរភាព**"។ **ផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា** ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវគ្រប់ជ្រុងជ្រោយមួយ និងការអន្តរាគមន៍ជាអន្តរវិស័យ ដើម្បីសម្រេចគោលដៅខាងលើនេះ។ រាជរដ្ឋាភិបាល ដែលមានក្រសួងពាក់ព័ន្ធជាសេនាធិការ នឹងធ្វើការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីលុបបំបាត់ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅកម្ពុជា ត្រឹមឆ្នាំ២០២៥។ នេះជាគោលដៅប្រកបដោយមហិច្ឆិតា ប៉ុន្តែខ្ញុំជឿជាក់យ៉ាងមុតមាំថា ÷ កម្ពុជាអាចបញ្ចប់ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ នៅកម្ពុជាបានដោយជោគជ័យ។

នៅឆ្នាំ២០១២ ឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ បានប្រកាសគំនិតផ្តួចផ្តើម ស្តីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ បន្ទាប់មកនៅឆ្នាំ២០១៣ គំនិតផ្តួចផ្តើម ស្តីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនេះ បានបន្តប្រកាសជាបន្តបន្ទាប់នៅតំបន់អាស៊ីប៉ាស៊ីហ្វិក និងមានការរៀបចំក្របខ័ណ្ឌណែនាំសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ ដែលបានរៀបចំដោយក្រុមការងារថ្នាក់តំបន់នៃអង្គការសហប្រជាជាតិ ស្តីពីភាពក្រីក្រ និងភាពអត់ឃ្លាននៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ក្រោមយន្តការសម្របសម្រួលថ្នាក់តំបន់នៃអង្គការសហប្រជាជាតិ។ ដោយឡែកនៅកម្ពុជា ការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ ត្រូវបានប្រកាសនៅខែឧសភា ឆ្នាំ២០១៥ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ រួមជាមួយប្រធានសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា និងជំនួយបច្ចេកទេសពីអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិប្រចាំកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ភាពអត់ឃ្លាននិងកង្វះអាហារូបត្ថម្ភ គឺជាបញ្ហាអន្តរវិស័យដែលទាមទារការឆ្លើយតបពីរាជរដ្ឋាភិបាលទាំងមូល និងត្រូវការនូវយន្តការសម្របសម្រួលហិរញ្ញវត្ថុសមស្រប និងការអនុវត្តប្រកបដោយប្រសិទ្ធភាព។ **ផែនការសកម្មភាពជាតិ សម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា** ផ្តល់ជាក្របខ័ណ្ឌសមស្របមួយសម្រាប់ការសម្របសម្រួលការងារ ដែលនឹងត្រូវអនុវត្តដោយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ក្នុងនោះក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើម្បីធានាឱ្យមានប្រភពធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការងារដ៏សំខាន់នេះ ហើយយើងក៏ទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់វិស័យឯកជន ក្នុងការជួយលុបបំបាត់ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅកម្ពុជាផងដែរ។

**ផែនការសកម្មភាពជាតិ សម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា** ត្រូវបានរៀបចំដោយផ្អែកលើគោលនយោបាយវិស័យពាក់ព័ន្ធ និងយុទ្ធសាស្ត្រនានាដែលមានរួចមកហើយ និងដើម្បីបំពេញបន្ថែមទៅលើគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យទាំងនោះ។ ក្នុងន័យនេះ ផែនការសកម្មភាពជាតិ មានគោលដៅគាំទ្រដល់សកម្មភាពចម្រុះ ដើម្បីលុបបំបាត់ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ត្រឹមឆ្នាំ២០២៥ នៅក្រោមការណែនាំនៃក្របខ័ណ្ឌរួមមួយ។ **ផែនការសកម្មភាពជាតិ សម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា** ចែកចេញជាបីផ្នែក គឺ÷ ផ្នែកទី១. បង្ហាញអំពីទិដ្ឋភាពរួមការកាត់បន្ថយភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅកម្រិតពិភពលោក តំបន់ និងថ្នាក់ជាតិ និងការឆ្លើយតបនានាចំពោះកម្មវិធីនេះ ផ្នែកទី២. បង្ហាញធាតុផ្សំសំខាន់ៗ ឬ សរសរស្តម្ភចំនួន៥ នៃផែនការសកម្មភាពនេះ និងផ្នែកទី៣. បង្ហាញពីយន្តការនានា សម្រាប់ការសម្របសម្រួលផែនការសកម្មភាពនេះ ការរៀបចំស្ថាប័ន ការកៀរគរនិងការបែងចែកធនធាន ការអនុវត្ត ការរាយការណ៍ និងការតាមដាន និងវាយតម្លៃ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល និងក្រសួងពាក់ពន្ធ័ដទៃទៀត ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល និងដឹកនាំការរៀបចំផែនការសកម្មភាពនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះសមាជិកទាំងអស់ នៃ**ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សា ផ្តល់នូវព័ត៌មាននានាសម្រាប់ការរៀបចំផែនការសកម្មភាពជាតិនេះ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជានិងប្រជាជនកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណចំពោះស្ថាប័នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា សមាជិកក្រុមការងារអង្គការសហប្រជាជាតិនៅកម្ពុជា រួមមានការិយាល័យអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិប្រចាំកម្ពុជា ការិយាល័យអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលបានផ្តល់ការគាំទ្រយ៉ាងមុតមាំ និងភាពជាដៃគូនៅក្នុងការរៀបចំ **ផែនការសកម្មភាពជាតិ សម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា** ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ**

វេជ្ជ. **យឹម ឆៃលី**

# អារម្ភកថា

ក្នុងនាមទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ខ្ញុំសូមសម្តែងការអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលមានការប្តេជ្ញាខ្ពស់ និងធ្វើការយ៉ាងសកម្ម នាំទៅរកការរៀបចំដោយជោគជ័យនូវ **ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា**។ ផែនការសកម្មភាពនេះ តំណាងឱ្យសសរស្តម្ភដ៏សំខាន់មួយនៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តរបៀបវារៈឆ្នាំ២០៣០នៃការអភិវឌ្ឍដោយចីរភាដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព(SDGs)។ខ្ញុំសូមថ្លែងអំណរគុណចំពោះការដឹកនាំរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដែលបានផ្តល់ការសម្របសម្រួលលើការងាររៀបចំផែនការ និងប្រមូលនូវធាតុចូលពីតួអង្គពាក់ព័ន្ធនានា នៅក្នុងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។

យើងទាំងអស់គ្នាទទួលស្គាល់ថាបញ្ហានានា ដែលទាក់ទងនឹងភាពអត់ឃ្លាននិងកង្វះអាហារូបត្ថម្ភនៅកម្ពុជា គឺជាកិច្ចការអន្តរវិស័យនិងទាមទារឱ្យមានការសម្របសម្រួលរវាងវិស័យនានាពីសំណាក់តួអង្គពាក់ព័ន្ធទាំងអស់។ ផែនការសកម្មភាពជាតិនេះនឹងសម្របសម្រួលដើម្បីដាក់បញ្ចូលនូវគោលនយោបាយនិងយុទ្ធសាស្ត្រតាមវិស័យនានាដូចជា៖ កសិកម្ម អភិវឌ្ឍន៍ជនបទ អប់រំ និងសុខាភិបាល ជាមួយបញ្ហាអន្តរវិស័យដែលរួមទាំងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ភាពធន់នឹងគ្រោះមហន្តរាយធម្មជាតិ និងសមភាពយេនឌ័រ។

ផែនការសកម្មភាពនេះ បានបន្សុីគ្រប់ជ្រុងជ្រោយជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០១៤-២០១៨ របស់កម្ពុជា។ ផែនការសកម្មភាពនេះ បន្ថែមគុណតម្លៃយ៉ាងច្រើនទៅក្នុងកិច្ចប្រឹងប្រែងរួមគ្នារបស់តួអង្គពាក់-ពន្ធ័ទាំងអស់ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់កម្ពុជា ដោយរួមបញ្ចូលសកម្មភាពនានា ដើម្បីលុបបំបាត់ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅក្រោមក្របខ័ណ្ឌរួមមួយ។ក្របខ័ណ្ឌនេះ ផ្តល់ការណែនាំគោលនយោបាយជាយុទ្ធសាស្ត្រសម្រាប់តួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលយ៉ាងមានប្រសិទ្ធភាព និងប្រសិទ្ធផលនូវកិច្ចប្រឹងប្រែងនានា ដើម្បីសម្រេចគោលបំណងរួមក្នុងការលុបបំបាត់ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅកម្ពុជា នៅត្រឹមឆ្នាំ២០២៥។

ក្រុមការងារអង្គការសហប្រជាជាតិ ជាពិសេស FAO, UNDP, UNICEF និង WFP រំពឹងថានឹងធ្វើការជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធសំខាន់ៗ នៅក្នុងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងជាមួយអង្គការសង្គមស៊ីវិល ដើម្បីអនុវត្ត**ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា** ឲ្យទទួលបានជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិនាឆ្នាំ២០១៦

**ឃ្លែរ វ៉ាន ឌឺ វ៉ារេន**

**អ្នកសម្របសម្រួលសហប្រជាជាតិ**

# មាតិកា

**ពាក្យបំព្រួញ** ........ viii

**សេចក្តីសង្ខេប** ........ xiii

**ផ្នែកទី១ ទិដ្ឋភាពរួមនៃសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ភាពអត់ឃ្លាននិងកង្វះអាហារូបត្ថម្ភ** ........ **១**

១.១ ការកាត់បន្ថយអសន្តិសុខស្បៀង ភាពអត់ឃ្លាន ........ ១

១.២ ការកាត់បន្ថយអសន្តិសុខស្បៀង ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ........ ២

១.៣ ការប្រកាសកម្មវិធីកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ ........ ៦

១.៤ ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា ........ ៧

១.៥ ដំណើរការ និងយន្តការស្ថាប័ននៃការរៀបចំផែនការសកម្មភាពជាតិ ........ ៨

**ផ្នែកទី២ ធាតុសំខាន់ៗនៃផែនការសកម្មភាព** ........ **១០**

២.១ គោលដៅរួមនៃផែនការសកម្មភាពជាតិ ........ ១០

២.២ វិស័យអាទិភាពនៃផែនការសកម្មភាពជាតិ - សសរស្តម្ភទាំងប្រាំ ........ ១១

ដ្យាក្រាម ២.១ - ធាតុផ្សំជាយុទ្ធសាស្ត្រនៃផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយភាព ........ ១២

សសរស្តម្ភ ១ – ការទទួលបានដោយសមធម៌ ១០០% នូវស្បៀងអាហារ ........ ១៣

លទ្ធផល ១.១ – ប្រជាពលរដ្ឋក្រីក្រ និងគ្មានទីពឹងមានសិទ្ធិទទួលបានស្បៀងអាហារ ........ ១៣

លទ្ធផល ១.២ –ផលប៉ះពាល់នៃការប្រែប្រួលថ្លៃស្បៀងត្រូវបានកាត់បន្ថយ ........ ១៤

សសរស្តម្ភ ២ – គ្មានករណីក្រិន (អត្រាក្រិន០%) ក្នុងចំណោមកុមារ ........ ១៤

លទ្ធផល ២.១ – គ្រួសារកម្ពុជា ជាពិសេស ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ........ ១៥

លទ្ធផល ២.២- សេវាសុខាភិបាលនិងអាហារូបត្ថម្ភដែលគាំទ្រដល់ការគាំពារមាតា និងទារក ........ ១៦

សសរស្តម្ភ ៣– ប្រព័ន្ធស្បៀងអាហារទាំងអស់មាននិរន្តរភាព ........ ១៧

លទ្ធផល ៣.១ - ស្តង់ដារនិរន្តរភាពត្រូវបានបង្កើតសម្រាប់កសិករ, កសិ-អាជីវកម្ម, សហគមន៍ ........ ១៧

លទ្ធផល ៣.២ - កសិកម្មដែលមាននិរន្តរភាព និងដែលធន់នឹងអាកាសធាតុត្រូវបានអនុវត្ត ........ ១៨

លទ្ធផល ៣.៣– ភាពស៊ីសង្វាក់គ្នានៃគោលនយោបាយរវាងវិស័យនានា ........ ១៩

សសរស្តម្ភ ៤ – កំណើន ១០០ភាគរយនៃផលិតភាព និងប្រាក់ចំណូល ........ ១៩

លទ្ធផល ៤.១ – ផលិតភាពរបស់កសិករខ្នាតតូច ត្រូវបានបង្កើន ........ ២០

លទ្ធផល ៤.២ – ប្រាក់ចំណូលរបស់ផលិតករតូចតាចតាមគ្រួសារ ........ ២១

សរសរស្តម្ភ ៥ – គ្មានការបាត់បង់ ឬ ខ្ជះខ្ជាយស្បៀងអាហារ ........ ២២
លទ្ធផល ៥.១ – ការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារ នៅក្នុងពេលប្រមូលផល ........ ២២

២.៣ សកម្មភាពអនុវត្ត, ការទទួលខុសត្រូវ និងថ្លៃចំណាយ ........ ២៣

**ផ្នែកទី ៣ យន្តការសម្របសម្រួល និងអនុវត្ត ........ ២៤**

៣.១ រចនាសម្ព័ន្ធស្ថាប័ន ........ ២៤
ក) តួនាទី និងការទទួលខុសត្រូវៈ ការសម្របសម្រួល ........ ២៥
ខ) គណៈកម្មការផ្តល់យោបល់ជាន់ខ្ពស់ ........ ២៥
គ) លេខាធិការដ្ឋានបច្ចេកទេសអចិន្ត្រៃយ៍ ........ ២៥
ឃ) ការសម្របសម្រួលថ្នាក់ក្រសួង/ស្ថាប័ន ........ ២៦

៣.២ ធនធាន ........ ២៦
៣.៣ កាលវិភាគនៃការអនុវត្ត ........ ២៨
៣.៤ ការរាយការណ៍, ការតាមដាន និងការវាយតម្លៃ ........ ២៩

**ផ្នែកទី ៤ សេចក្តីសន្និដ្ឋាន ........ ៣១**

**ឧបសម្ព័ន្ធ ១ តារាងឡុក់ហ្វ្រេម (Log Frame) លទ្ធផល, ធាតុចេញ និងសកម្មភាព ........ ៣១**
សេចក្តីពន្យល់អំពីជាតុផ្សំនានាក្នុងឡុក់ហ្វ្រេម (Log Frame) ........ ៣១

**ឧបសម្ព័ន្ធ ២ តារាងលទ្ធផលដើម្បីសម្រេចបានការកាត់បន្ថយភាពអត់ឃ្លាន ........ ៣៣**
សរសរស្តម្ភ១ ការទទួលបានដោយសមធម៌ ១០០% នូវស្បៀងអាហារប្រកបដោយសារជាតុ ........ ៣៣

សរសរស្តម្ភ២ គ្មានករណីក្រិនក្នុងចំណោមកុមារដែលមានអាយុតិចជាង ២ ឆ្នាំ ........ ៤៥
សរសរស្តម្ភ៣ ប្រព័ន្ធស្បៀងអាហារទាំងអស់មាននិរន្តរភាព ........ ៥៧
សរសរស្តម្ភ៤ កំណើន ១០០%នៃផលិតភាព និងប្រាក់ចំណូលរបស់គ្រួសារកសិករតូចតាច ........ ៦៥
សរសរស្តម្ភ៥ គ្មានការបាត់បង់ ឬ ខ្ជះខ្ជាយស្បៀងអាហារ ........ ៧២

**ឧបសម្ព័ន្ធ ៣ គោលនយោបាយ និងយុទ្ធសាស្ត្រជាតិដែលពាក់ព័ន្ធ ........ ៧៥**

# ពាក្យបំព្រួញ

| | | |
|---|---|---|
| ACIAR | Australian Centre for International Agricultural Research | មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AIFS | ASEAN Integrated Food Security Framework | ក្របខ័ណ្ឌសន្តិសុខស្បៀងចម្រុះអាស៊ាន |
| ANC | Ante Natal Care | ការថែទាំមុនពេលសម្រាល |
| ARD | Agriculture and Rural Development | ការអភិវឌ្ឍកសិកម្ម និងជនបទ |
| ASDP | Agriculture Sector Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ASP | Adaptive Social Protection | កិច្ចគាំពារសង្គមបែបបន្ស៊ាំ |
| AusDFAT | Australian Department for Foreign Affairs and Trade | ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី |
| CARD | Council for Agricultural and Rural Development | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ |
| CARDI | Cambodia Agriculture Research and Development Institute | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CCCSP | Cambodia Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា |
| CDC | Council for the Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDCS | Cambodia Development Cooperation Strategy | យុទ្ធសាស្ត្រសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា |
| CDHS | Cambodia Demographic Health Survey | ការអង្កេតប្រជាសាស្ត្រនិងសុខភាព នៅកម្ពុជា |
| CEDAW | Convention on the Elimination of All Forms of Discrimination Against Women | អនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងមកលើស្ត្រី |
| CCSP-WRM | Climate Change Strategic Plan for Water Resource Management, 2013-2017 | ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់ការគ្រប់គ្រងធនធានទឹក 2013-2017 |
| CMAA | Cambodia Mine Action Authority | អាជ្ញាធរសកម្មភាពមីនកម្ពុជា |
| CBNP | Community Based Nutrition Program | កម្មវិធីអាហារូបត្ថម្ភផ្អែកលើសហគមន៍ |
| COP21 | 21st Annual Conference of Parties | សន្និសីទភាគីប្រចាំឆ្នាំលើកទី ២១ |
| CRC | Convention on the Rights of the Child | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| CSOs | Civil Society Organizations | អង្គការសង្គមស៊ីវិល |
| CU5 | Children Under Five (Years of Age) | កុមារអាយុក្រោមប្រាំឆ្នាំ |

| | | |
|---|---|---|
| DAE | Department of Agriculture Extension | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| DAHP | Department of Animal Health and Production | នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល |
| DAI | Department of Agro-Industry | នាយកដ្ឋានកសិ-ឧស្សាហកម្ម |
| DPs | Development Partners | ដៃគូអភិវឌ្ឍន៍ |
| ESCAP | (UN) Economic and Social Commission for Asia and the Pacific | គណៈកម្មការសេដ្ឋកិច្ចនិងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក(នៃអង្គការសហប្រជាជាតិ) |
| EU | European Union | សហភាពអឺរ៉ុប |
| FAO | Food and Agriculture Organization of the United Nations | អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ |
| FSC | Food Supply Chains | ខ្សែចង្វាក់ផ្គត់ផ្គង់ស្បៀងអាហារ |
| FSNCU | Food Security and Nutrition Coordination Unit | អង្គភាពសម្របសម្រួលសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ |
| FTRM | Fast Track Road Map | ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿន |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| FoA | Forestry Administration | រដ្ឋបាលព្រៃឈើ |
| GAP | Good Agricultural Practices | ការអនុវត្តល្អក្នុងវិស័យកសិកម្ម |
| GDA | General Directorate for Agriculture | អគ្គនាយកដ្ឋានកសិកម្ម |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit | ទីភ្នាក់ងារអាល្លឺម៉ង់ដើម្បីសហប្រតិបត្តិការអន្តរជាតិ |
| HEFs | Health Equity Funds | មូលនិធិសមធម៌សុខភាព |
| ICESRC | International Covenant on Economic, Social, and Cultural Rights | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិទទួលបានសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| IFAD | International Fund for Agriculture Development | មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍កសិកម្ម |
| ILO | International Labour Organization | អង្គការពលកម្មអន្តរជាតិ |
| IMP | Integrated Pest Management | វិធានការចម្រុះការពារដំណាំ |
| IRRI | International Rice Research Institute | វិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ |
| ICT | Information and Communication Technology | បច្ចេកវិទ្យាព័ត៌មាននិងការប្រាស្រ័យទាក់ទង |
| JICA | Japan International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| JMIs | Joint Monitoring Indicators | សូចនាករតាមដានរួមគ្នា |
| M & E | Monitoring and Evaluation | ការត្រួតពិនិត្យ និងវាយតម្លៃ |

| | | |
|---|---|---|
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ML-MUPC | Ministry of Land Management, Urban Planning, and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ |
| MoC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoEYS | Ministry of Education, Youth, and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| MoIH | Ministry of Industry and Handicrafts | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoLVT | Ministry of Labour and Vocational Training | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoSAVY | Ministry of Social Affairs, Veterans, and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| MoT | Ministry of Tourism | ក្រសួងទេសចរណ៍ |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| MoW-RaM | Ministry for Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NAP | National Action Plan | ផែនការសកម្មភាពជាតិ |
| NAPHM-FC | National Action Plan for a Hunger and Malnutrition Free Cambodia | ផែនការសកម្មភាពជាតិសម្រាប់កម្ពុជាគ្មានភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ |
| NCDDS | National Committee for Democratic Development Secretariat | លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |
| NGOs | Non-Governmental Organizations | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | National Institute for Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ |
| NSFSN | National Strategy for Food Security and Nutrition | យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ |
| NSPS | National Social Protection Strategy | យុទ្ធសាស្រ្តជាតិគាំពារសង្គម |
| NTFP | Non-Timber Forest Products | អនុផលព្រៃឈើ |

| | | |
|---|---|---|
| PBA | Program Based Approach | អភិក្រមផ្អែកលើកម្មវិធី |
| PD-WRaMs | Province Department of Water Resources and Meteorology | មន្ទីរធនធានទឹកនិងឧតុនិយមខេត្ត |
| PWP | Public Works Program | កម្មវិធីការងារសាធារណៈ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RS III | Rectangular Strategy III | យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ |
| RUA | Royal University of Agriculture | សកលវិទ្យាល័យភូមិន្ទកសិកម្ម |
| RWSSH | Rural Water Supply, Sanitation, and Hygiene | ការផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ |
| SAM | Severe Acute Malnutrition | កង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរ |
| SAW | Strategy for Agriculture and Water | យុទ្ធសាស្ត្រកសិកម្មនិងទឹក |
| SDG | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ដោយចីរភាព |
| SIDA | Swedish International Development Agency | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| SME | Small, Medium Enterprise | សហគ្រាសខ្នាតតូចនិងមធ្យម |
| SPFL | Strategic Planning Framework for Livestock, | ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ការចិញ្ចឹមសត្វ |
| SUN | Scaling Up Nutrition Movement | ចលនាបង្កើនអាហារូបត្ថម្ភ |
| TBD | To Be Determined | រង់ចាំការបញ្ជាក់ |
| TDSP | Tourism Development Strategic Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ |
| TVET | Technical and Education Vocational Training | ការបណ្តុះបណ្តាលបច្ចេកទេសនិងអប់រំវិជ្ជាជីវៈ |
| TWG | Technical Working Group | ក្រុមការងារបច្ចេកទេស |
| TWG/A & W | Technical Working Group for Agriculture and Water | ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក |
| TWG/SP&FSN | Technical Working Group for Social Protection, Food Security and Nutrition | ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ |
| UN | United Nations | អង្គការសហប្រជាជាតិ |
| UNDAF | United Nations Development Assistance Framework | ក្របខ័ណ្ឌហិរញ្ញប្បទានអភិវឌ្ឍន៍សហប្រជាជាតិ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNESCO | United Nations Educational, Scientific, and Cultural Organization | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌សហប្រជាជាតិ |
| UNICEF | United Nations Children Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |

| | | |
|---|---|---|
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| WASH | Water, Sanitation, and Hygiene | ការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ |
| WB | World Bank | ធនាគារពិភពលោក |
| WFP | World Food Programme | កម្មវិធីស្បៀងពិភពលោក |
| WHO | World health Organization | អង្គការសុខភាពពិភពលោក |
| ZHC | Zero Hunger Challenge | គំនិតផ្តួចផ្តើមស្តីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ |

# សេចក្ដីសង្ខេប

ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជាបានឆ្លុះបញ្ចាំងអំពីការប្ដេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដើម្បី "បញ្ចប់ភាពអត់ឃ្លាន, សម្រេចបានសន្តិសុខស្បៀង និងកែលម្អអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព" ។ ផែនការសកម្មភាពជាតិស្ដីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា បានផ្ដល់ជាផែនទីបង្ហាញផ្លូវពេញលេញនិងចម្រុះមួយដើម្បីសម្រេចគោលដៅខាងលើស្របតាមយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

លោក **បាន គីមូន** អគ្គលេខាធិការអង្គការសហប្រជាជាតិ បានប្រកាសគំនិតផ្ដួចផ្ដើម ស្ដីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ (ZHC) នៅក្នុងសន្និសីទ រីយ៉ូ ២០+ ស្ដីពីការអភិវឌ្ឍន៍ប្រកបដោយចីរភាព នាខែមិថុនា ឆ្នាំ២០១២ កន្លងទៅដែលនៅទីនោះ លោកបានប្រកាសចក្ខុវិស័យរបស់លោកសម្រាប់អនាគត-**ពិភពលោកមួយដែលចាកផុតពីភាពអត់ឃ្លាន និង កង្វះអាហារូបត្ថម្ភ**។ ការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ ត្រូវបានប្រកាសជាបន្តនៅកម្ពុជានា ខែឧសភា ឆ្នាំ២០១៥ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (CARD) រួមជាមួយប្រធានសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា។ ចក្ខុវិស័យនៃគំនិតផ្ដួចផ្ដើមស្ដីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនេះ បានឆ្លុះបញ្ចាំងនៅក្នុងសរសរស្តម្ភទាំងប្រាំ ដែលបានកំណត់អត្តសញ្ញាណលទ្ធផលសំខាន់ៗ ដែលត្រូវបានគាំទ្រយ៉ាងទូលំទូលាយលើសកម្មភាពនានាដូចជា៖

- ការទទួលបានស្បៀងអាហារគ្រប់គ្រាន់ ១០០% ពេញមួយឆ្នាំ
- គ្មានករណីក្រិនចំពោះកុមារមានអាយុក្រោម២ឆ្នាំ
- ប្រព័ន្ធស្បៀងអាហារទាំងអស់មាននិរន្តរភាព
- ផលិតកម្ម និង ប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូចមានកំណើន១០០%
- គ្មានការបាត់បង់ ឬ ខ្ជះខ្ជាយស្បៀងអាហារ។

ផែនការសកម្មភាពជាតិ ស្ដីពីគំនិតផ្ដួចផ្ដើម អំពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា បានបន្សុីគ្នាយ៉ាងពេញលេញជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤ - ២០១៨។ ផែនការនេះក៏បានបន្តនិងបំពេញបន្ថែមទៅលើគោលនយោបាយ និង យុទ្ធសាស្ត្រតាមវិស័យជាក់លាក់ និងពហុវិស័យនានាៗ ដែលមានស្រាប់។ អាស្រ័យហេតុនេះ ផែនការសកម្មភាពជាតិមានគោលបំណងគាំទ្រដល់សកម្មភាពចំរុះសំដៅកាត់បន្ថយភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅត្រឹម

ឆ្នាំ២០២៥ ក្រោមគោលការណ៍នាំនៃក្របខ័ណ្ឌរួមមួយ ។ លើសពីនេះទៀត ផែនការសកម្មភាពជាតិនឹងត្រូវអនុវត្តដោយស្ថាប័នរដ្ឋាភិបាល ។ CARD មានអាណត្តិជាអ្នកសម្របសម្រួលការងារដែលនឹងត្រូវអនុវត្តដោយក្រសួងពាក់ព័ន្ធនានា ។ CARD នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដើម្បីធានាបាននូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់។ CARD ក៏ទទួលស្គាល់ផងដែរអំពីតួនាទីដ៏សំខាន់របស់វិស័យឯកជន ក្នុងការជួយលុបបំបាត់ភាពអត់ឃ្លាននិងកង្វះអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា។

ជាជំហានបន្តយើងមានការកិច្ចសំខាន់ជាច្រើនដែលត្រូវដោះស្រាយ ក្នុងដំណាក់កាលអនុវត្តដំបូង។ ជាពិសេស គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវធ្វើការយ៉ាងជិតស្និទ្ធរួមគ្នា សំដៅសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងដើម្បីគៀងគរធនធាន និង ធានាឱ្យបានការវិនិយោគប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធិផលក្នុងការដោះស្រាយបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រកបដោយចីរភាព។ ការយកចិត្តទុកដាក់លើការអភិវឌ្ឍយន្តការសម្របសម្រួលឱ្យកាន់តែខ្លាំងនៅគ្រប់វិស័យ នឹងត្រូវយកចិត្តទុកដាក់បន្ថែមទៀតដើម្បីសំដៅធានាឱ្យបាននូវគោលនយោបាយ និង យុទ្ធសាស្ត្រជាក់លាក់នានាត្រូវបានរៀបចំឡើង ដើម្បីសម្រេចបាននូវការវិនិយោគដែលមានភាពស៊ីសង្វាក់គ្នា និងមានលក្ខណៈបំពេញបន្ថែមគ្រប់ជ្រុងជ្រោយ ។ ការអភិវឌ្ឍក្របខ័ណ្ឌដ៏ទូលំទូលាយនិងរឹងមាំសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃមានសារៈសំខាន់ជាពិសេស ក្នុងការធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាព ទាក់ទងនឹងការខិតខំប្រឹងប្រែងរួមគ្នារបស់ភាគីពាក់ព័ន្ធទាំងអស់ ។ ភាគីពាក់ព័ន្ធ ក៏ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពនៅគ្រប់កម្រិតទាំងអស់ទាំងក្នុងរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិលអំពីបញ្ហាទាក់ទងនឹងវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ។ ការងារនេះ នឹងតម្រូវឱ្យមានចំណេះដឹងបន្ថែមទៀតអំពីទិដ្ឋភាពជាក់លាក់នៃខ្សែសង្វាក់ផ្គត់ផ្គង់ស្បៀង ក៏ដូចជាទិដ្ឋភាពសេដ្ឋកិច្ចសង្គម ដែលទាក់ទងនឹងភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា។

នៅពេលដែលតួនាទីចម្បងទាំងនេះត្រូវបានបំពេញ រាជរដ្ឋាភិបាលកម្ពុជាតំណាងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួងពាក់ព័ន្ធដៃគូអភិវឌ្ឍន៍នានា អង្គការសង្គមស៊ីវិល រួមគ្នាបន្តអនុវត្តផែនការដើម្បីកាត់បន្ថយភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជានៅបំណាច់ឆ្នាំ២០២៥។

# ផ្នែកទី ១ និន្នាការរួមនៃសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ

## ១.១ ការកាត់បន្ថយអសន្តិសុខស្បៀង ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ - នៅថ្នាក់តំបន់ និងពិភពលោក

សន្តិសុខស្បៀង និងអាហារូបត្ថម្ភ កើតមានឡើង "**នៅពេលដែលប្រជាពលរដ្ឋគ្រប់រូបមានលទ្ធភាពផ្នែករូបវន្តសង្គម និងសេដ្ឋកិច្ចប្រសើរជាងមុន ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភគ្រប់ពេលវេលា ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់**"។[1] កិច្ចប្រជុំកំពូលពិភពលោកស្តីពីស្បៀងអាហារនៅឆ្នាំ ១៩៩៦ បានកំណត់ចំណុចដៅនៃការកាត់បន្ថយឲ្យបានពាក់កណ្តាលនូវចំនួនប្រជាពលរដ្ឋដែលពុំមានអាហារូបត្ថម្ភគ្រប់គ្រាន់នៅត្រឹមឆ្នាំ២០១៥ ដោយផ្អែកលើចំនួនដែលបានកត់ត្រានៅឆ្នាំ១៩៩២។ នៅទូទាំងពិភពលោកមានប្រជាជនប្រមាណ៧៩៥លាននាក់ ដែលពុំសម្រេចបានតាមលក្ខណៈវិនិច្ឆ័យនេះ។ នៅឆ្នាំ ២០១៥ មានប្រជាជនប្រមាណ ៥១២ លាននាក់កំពុងអត់ឃ្លាន និងពុំមានអាហារូបត្ថម្ភគ្រប់គ្រាន់ (ឬពីរភាគបីនៃចំនួនសរុបនេះ) ស្ថិតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ នៅតំបន់អាស៊ី កុមារអាយុក្រោមប្រាំឆ្នាំ ប្រមាណ ១០០លាននាក់ មានភាពក្រិន។ ភាពអត់ឃ្លាន (ពុំមានស្បៀងអាហារគ្រប់គ្រាន់) និងកង្វះអាហារូបត្ថម្ភ (លក្ខខណ្ឌដែលកើតឡើងនៅពេលដែលរាងកាយពុំបានទទួលបរិមាណគ្រប់គ្រាន់នៃកាឡូរី ជីវជាតិ សារធាតុរ៉ែ និងសារជាតិចិញ្ចឹមដទៃទៀតដែលរាងកាយត្រូវការ ដើម្បីរក្សាជាលិកានិងសរីរាង្គឱ្យមានសុខភាពល្អ) គឺជាមូលហេតុចំបងនៃការបាត់បង់ជីវិតរបស់មនុស្សជាច្រើនលាននាក់ក្នុងមួយឆ្នាំៗនៅលើពិភពលោក។ កុមារតូចៗ ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន គឺជាក្រុមងាយរងគ្រោះបំផុត ដែលទទួលរងផលប៉ះពាល់។ កង្វះអាហារូបត្ថម្ភ គឺជាមូលហេតុលាក់កំបាំងនៃការបាត់បង់ជីវិតរបស់កុមារ៣,៥លាននាក់ ហើយត្រូវជាមួយភាគបី(១/៣)នៃកុមារដែលមានជំងឺ។ កង្វះលទ្ធភាពក្នុងការទទួលបានអាហារដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ និងការថែទាំសុខភាព ធ្វើឱ្យខូចសក្តានុពលនៃការអភិវឌ្ឍជាតិ និងគំរាមកំហែងដល់សុខភាពសាធារណៈ និងសន្តិសុខសង្គម។ ទោះបីចំនួនប្រជាជនដែលមានភាពអត់ឃ្លាន និង/ឬកង្វះអាហារូបត្ថម្ភបានថយចុះនៅក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះក៏ដោយ ក៏ជារួមពិភពលោកមិនបានធ្វើឱ្យមានវឌ្ឍនភាពក្នុងការសម្រេចឲ្យបានគោលដៅដែលបានគ្រោងទុកគឺ **ពិភពលោកមួយគ្មានភាពអត់ឃ្លាននិងកង្វះអាហារូបត្ថម្ភ**នោះឡើយ។

---

[1] សេចក្តីប្រកាសនៃកិច្ចប្រជុំកំពូលពិភពលោក ឆ្នាំ ១៩៩៦

សិទ្ធិចំពោះស្បៀងអាហារ គឺជាសិទ្ធិមនុស្សដែលមានការទទួលស្គាល់ជាអន្តរជាតិ។ សិទ្ធិនេះមានចែងនៅក្នុងសេចក្តីប្រកាសជាសកលឆ្នាំ១៩៤៨ ស្តីពីសិទ្ធិមនុស្ស ក៏ដូចជា សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR)ផងដែរ។ សេចក្តីប្រកាស និងសន្ធិសញ្ញាអន្តរជាតិមួយចំនួន ដូចជា សេចក្តីប្រកាសអន្តរជាតិស្តីពីអាហារូបត្ថម្ភ កិច្ចប្រជុំកំពូលពិភពលោកស្តីពីស្បៀងអាហារ និងកិច្ចប្រជុំកំពូលពិភពលោកស្តីពីស្បៀងអាហារ+៥ បានទទួលស្គាល់ពីតម្រូវការរបស់ប្រទេសនានាក្នុងការគោរព និងលើកស្ទួយសិទ្ធិបុគ្គលគ្រប់រូប ក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ មានអាហារូបត្ថម្ភ និងសុវត្ថិភាព។ លើសពីនេះ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងចំពោះស្ត្រី (CEDAW) ចែងអំពីសិទ្ធិជាពិសេស របស់ក្រុមងាយរងគ្រោះបំផុតដែលរួមមាន កុមារ និងស្ត្រី។ ដូចដែលបានជម្រាបជូនខាងលើ កិច្ចប្រជុំកំពូលពិភពលោកស្តីពីស្បៀងអាហារក្នុងឆ្នាំ១៩៩៦ បានកំណត់ចំណុចគោលដៅ ដើម្បីកាត់បន្ថយឱ្យបានពាក់កណ្តាលនូវចំនួនប្រជាជនដែលមានអាហារូបត្ថម្ភមិនគ្រប់គ្រាន់ នៅត្រឹមឆ្នាំ២០១៥។ នៅឆ្នាំ២០០៤ ក្រុមប្រឹក្សាភិបាលនៃអង្គការ FAO បានអនុម័តជាឯកច្ឆ័ន្ទនូវគោលការណ៍ណែនាំស្ម័គ្រចិត្ត ដើម្បីគាំទ្រដល់សមិទ្ធកម្មកាន់តែច្រើនឡើងនៃសិទ្ធិក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ នៅក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ។

នៅខែកញ្ញា ឆ្នាំ២០១៥ រដ្ឋសមាជិកអង្គការសហប្រជាជាតិ បានអនុម័តគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDGs) ជាផ្នែកមួយនៃរបៀបវារៈថ្មីរបស់ពិភពលោក នៃការអភិវឌ្ឍដោយចីរភាពដែលបានរៀបចំឡើងនៅក្នុងសន្និសីទភាគីប្រចាំឆ្នាំលើកទី២១ (COP21)។ គោលដៅទី២ នៃ SDGs មានការពាក់ព័ន្ធជាពិសេស ចំពោះគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ ដែលទាក់ទងនឹងការអំពាវនាវឱ្យ"**បញ្ចប់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀង កែលម្អអាហារូបត្ថម្ភនិងលើកកម្ពស់កសិកម្មដែលមាននិរន្តរភាព**"។

## ១.២ ការកាត់បន្ថយអសន្តិសុខស្បៀង ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ - នៅថ្នាក់ជាតិ

រាជរដ្ឋាភិបាលកម្ពុជា គឺជាហត្ថលេខីនៃអនុសញ្ញាអន្តរជាតិ ដែលបានផ្តល់ក្របខ័ណ្ឌច្បាប់សម្រាប់ការទទួលស្គាល់សន្តិសុខស្បៀង ថាជាសិទ្ធិមូលដ្ឋានរបស់បុគ្គល នៅក្រោមច្បាប់អន្តរជាតិ ជាពិសេសសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ រាជរដ្ឋាភិបាលកម្ពុជា ក៏ប្រកាន់ខ្ជាប់នូវ"**គោលការណ៍ស្ម័គ្រចិត្ត ដើម្បីគាំទ្រដល់សមិទ្ធកម្មកាន់តែច្រើនឡើងនៃសិទ្ធិក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់នៅក្នុងបរិបទនៃសន្តិសុខស្បៀងរបស់ជាតិ**"ផងដែរ ដែលបានអនុម័តដោយរដ្ឋសមាជិក FAO ចំនួន១៨៧ប្រទេស នៅខែវិច្ឆិកាឆ្នាំ២០០៤។ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាប្រកាន់យកក្របខ័ណ្ឌសន្តិសុខស្បៀងចម្រុះអាស៊ាន (AIFS) និងផែនការសកម្មភាពយុទ្ធសាស្ត្រស្តីពីសន្តិសុខ

ស្បៀង។ កម្ពុជាក៏បានចូលជាសមាជិកមួយនៃចលនាពង្រីកកិច្ចអន្តរាគមន៍អាហារូបត្ថម្ភពិភពលោក (SUN Movement) តាំងពីខែកក្កដា ឆ្នាំ២០១៤ ផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាយ៉ាងសកម្មក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs)។ បន្ថែមលើការសម្រេចគោលដៅទី១ "**លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ**" រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា សន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានតួនាទីដ៏សំខាន់ក្នុងការសម្រេចគោលដៅដទៃទៀតជាច្រើនក្នុងចំណោម MDGs ទាំងប្រាំបីរបស់កម្ពុជា។ គោលដៅទាំងនោះរួមមានកំណើនសិស្សចូលរៀន, ការលើកកម្ពស់សមធម៌យេនឌ័រ និងការពង្រឹងការផ្តល់សិទ្ធិដល់ស្ត្រី, ការកាត់បន្ថយមរណភាពកុមារ, ការកែលម្អការគាំពារសុខភាពមាតា, និងការធានាចីរភាពបរិស្ថាន។ ដោយសារតែអត្រាខ្ពស់នៃគ្រាប់មីនបង្កប់ក្នុងដី កម្ពុជាបានបន្ថែមការបោសសំអាតគ្រាប់មីនជា MDG ទី៩។ វឌ្ឍនភាពគួរឱ្យកោតសរសើរដែលសម្រេចបាននៅក្នុងវិស័យនេះ បាននាំឱ្យគ្រួសារក្រីក្រ និងងាយរងគ្រោះមានដីធ្លីប្រើប្រាស់សម្រាប់ផលិតកម្មកាន់តែច្រើនឡើង។ ប្រការនេះបានជួយបង្កើនសន្តិសុខស្បៀងនិងក្នុងចំណោមគ្រួសារក្រីក្រ និងដែលងាយរងគ្រោះ។

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាផ្នែកដ៏សំខាន់មួយនៃការអភិវឌ្ឍមូលធនមនុស្ស និងកំណើនសេដ្ឋកិច្ចដោយចីរភាព ជាពិសេស នៅក្នុងអំឡុងសិក្ខាសាលាថ្នាក់ជាតិលើកទី៣ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្រោមប្រធានបទ "**បណ្តាញសុវត្ថិភាពសង្គម**" កាលពីខែកក្កដា ឆ្នាំ២០០៩ ក៏ដូចជាក្នុងសិក្ខាសាលាថ្នាក់ជាតិលើកទី៤ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោមប្រធានបទ "**អាហារូបត្ថម្ភសម្រាប់មាតានិងទារក**" ដែលបានរៀបចំឡើងកាលពីខែឧសភា ឆ្នាំ២០១២។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវបានប្រគល់អាណត្តិដើម្បី "**រៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបាន និងផែនការសកម្មភាពដើម្បីបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភ**"។ សិក្ខាសាលាថ្នាក់ជាតិលើកទី៥ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលបានធ្វើឡើងនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ គឺបានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការនូវ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨**។ សិក្ខាសាលានេះ ក៏បានផ្តល់អនុសាសន៍សម្រាប់**អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ឱ្យកាន់តែមានប្រសិទ្ធភាព រួមទាំងការកំណត់ឲ្យមាន**ទិវាជាតិអាហារូបត្ថម្ភ** ដែលត្រូវរៀបចំឡើងជារៀងរាល់ឆ្នាំ នៅថ្ងៃទី៦ ខែវិច្ឆិកា ដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីអាហារូបត្ថម្ភ។ ព្រឹត្តិការណ៍ទាំងបីលើកនេះ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ នៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ សំដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព (២០១៤-២០១៨) ចែងអំពីទិសដៅនយោបាយដ៏ធំទូលាយដើម្បីកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ កំណត់អាទិភាពសម្រាប់ការពង្រីកវត្តមាន, ការទទួលបាន, ការប្រើប្រាស់ និងស្ថិរភាពស្បៀងអាហារ ជាពិសេស នៅក្នុងចតុកោណដែលផ្តោតលើប្រពលវប្បកម្ម និងពិពិធកម្មកសិកម្ម កំណែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព ការពង្រីកសុខុមាលភាព និងអាហារូបត្ថម្ភ និងការបង្កើតបណ្តាញសុវត្ថិភាពសង្គម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ (NSDP) បានប្រតិបត្តិតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងបានកំណត់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាបញ្ហាអន្តរវិស័យដ៏សំខាន់មួយ។ NSDP ចែងអំពីសកម្មភាពពាក់ព័ន្ធនានា ដើម្បីពង្រីកនូវភាពមានស្បៀង ការទទួលបានស្បៀង ការការប្រើប្រាស់ និងការបឺតស្រូបស្បៀង និងស្ថិរភាពនៃការផ្គត់ផ្គង់ស្បៀង។ សកម្មភាពនានា ដើម្បីពង្រីកបរិយាកាសនយោបាយ និងគោលនយោបាយសម្រាប់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក៏មានចុះបញ្ចាំងនៅក្នុង NSDP ជាមួយនឹងសូចនាករលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានរៀបចំ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** (NSFSN) មានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ ដែលបានកំណត់ច្បាស់លាស់នូវវិស័យសកម្មភាពជាអាទិភាព។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក៏បានរៀបចំ**យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា** (NSSP) ដែលបំពេញបន្ថែមលើ NSFSN ផងដែរ។ **គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨** (ASDP) ចែងអំពីផែនការយុទ្ធសាស្ត្រសម្រាប់បង្កើនផលិតកម្មស្បៀង។ ផែនការអភិវឌ្ឍន៍វិស័យសុខាភិបាលដូចមានចែងនៅក្នុងផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿន ការកែលម្អអាហារូបត្ថម្ភ (២០១៤-២០២០) ផ្តោតការយកចិត្តទុកដាក់លើវិស័យអាទិភាពនានា ដែលពាក់ព័ន្ធជាមួយការកែលម្អលទ្ធផលការគាំពារមាតានិងទារក និងអាហារូបត្ថម្ភ ដែលរួមទាំងការកាត់បន្ថយភាពក្រិនផងដែរ។ ផែនការនារីរតនៈ IV ក៏ផ្តល់ផងដែរនូវការណែនាំដ៏មានប្រយោជន៍សម្រាប់លើកកម្ពស់ការពង្រឹងសិទ្ធិអំណាចខាងសេដ្ឋកិច្ចរបស់ស្ត្រីដែលជាលទ្ធផលនាំឱ្យស្ថានភាពមាតា និងទារកប្រសើរជាងមុន។

រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថាកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍(DPs) ដែលរួមមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ (NGO) បានផ្តល់ផលប្រយោជន៍ជាច្រើន ដើម្បីដោះស្រាយបញ្ហាសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ ទាំងការរៀបចំផែនការសកម្មភាព និងហិរញ្ញវត្ថុ ជំនួយបច្ចេកទេស និងការអនុវត្ត។ ការសម្របសម្រួលជាមួយ DPs នៅក្រោមការដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានធ្វើឡើងតាមរយៈយន្តការក្រុមការងារបច្ចេកទេសចម្រុះ (TWG) នៃរាជរដ្ឋាភិបាលកម្ពុជា។ ក្រុមការងារបច្ចេកទេសពាក់ព័ន្ធនានា រួមមាន៖ ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និង អាហារូបត្ថម្ភ, សុខភាព, កសិកម្ម និងទឹក, យេនឌ័រ, ជលផល, ព្រៃឈើ និងបរិស្ថាន,ទឹកស្អាត និងអនាម័យជនបទ។

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ផងដែរនូវតួនាទីដ៏សំខាន់របស់វិស័យឯកជន ក្នុងការដោះស្រាយបញ្ហានានា ដែលទាក់ទងនឹងវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ បញ្ហាគន្លឹះរួមមាន ការងារ និងឱកាសរកប្រាក់ចំណូល ការវិនិយោគកាន់តែច្រើនលើបច្ចេកវិទ្យាផលិត និងបច្ចេកវិទ្យាកែច្នៃកសិផលប្រកបដោយប្រសិទ្ធផល និងការផ្តល់ស្បៀងអាហារដែលមានសុវត្ថិភាព និងអាហារប្រកបដោយសារជាតុចិញ្ចឹមគ្រប់គ្រាន់សម្រាប់អ្នកបរិភោគ។ វិស័យឯកជនក៏ផ្តល់ឱកាសសំខាន់ៗ ដែលគាំទ្រដល់ការពង្រឹងសិទ្ធិអំណាចខាងសេដ្ឋកិច្ចរបស់ស្ត្រីផងដែរ។ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម (IDP) របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានប្រកាសដាក់ឲ្យអនុវត្តន៍ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាពេលថ្មីៗនេះ ផ្តល់ការណែនាំសំខាន់ៗ សម្រាប់សមាហរណកម្មការវិនិយោគនៃវិស័យឯកជន ទៅក្នុងគោលដៅអភិវឌ្ឍន៍ជាតិរបស់កម្ពុជា ដែលរួមទាំងការកែច្នៃស្បៀងអាហារក្នុងអាជីវកម្មកសិកម្មផងដែរ។

កត្តាទាំងនេះនិងកត្តាផ្សេងទៀត បានបង្កើតនូវសមិទ្ធផលសំខាន់ៗក្នុងការកាត់បន្ថយភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ថ្វីត្បិតតែមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រ និងសមិទ្ធផលនានានៅក្នុងគោលដៅផ្សេងនៃ CMDGs ក៏ដោយក៏បញ្ហាក្រិន និងសូចនាករដទៃទៀតអំពីកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារតូចៗ នៅតែមានកម្រិតខ្ពស់នៅឡើយ។ ឧទាហរណ៍ ការអង្កេតប្រជាសាស្ត្រនិងសុខភាពប្រជាជនកម្ពុជាឆ្នាំ២០១៤ (CDHS) បានបង្ហាញថា ៣២ ភាគរយនៃកុមារអាយុក្រោម៥ ឆ្នាំ គឺមានភាពក្រិន (ពោលគឺ មានកំពស់ទាបធៀបនឹងអាយុ)។ តួលេខនេះបង្ហាញថាមានការថយចុះត្រឹមតែ ៨ ភាគរយ ប៉ុណ្ណោះ បើប្រៀបធៀបនឹងការអង្កេត CDHS នៅឆ្នាំ ២០១០ ។ លើសពីនេះ កុមារ ៩ ភាគរយក្នុងវ័យនេះ មានសភាពក្រិនធ្ងន់ធ្ងរ។ ទាក់ទងនឹងភាពស្គមស្គាំង(ផលធៀបរវាងទម្ងន់និងកំពស់) កុមារ១០ ភាគរយ មានសភាពស្គមស្គាំង

បើផ្អែកតាម CDHS, ធៀបនឹង ១១ ភាគរយនៅឆ្នាំ២០១០។ ភាគរយនៃកុមារមិនគ្រប់ទម្ងន់ (ទម្ងន់ធៀបនឹងអាយុ) បានកែលម្អតិចតួចរវាងឆ្នាំ២០១០ និង២០១៤។

## ១.៣ ការប្រកាសកម្មវិធីកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ ដោយអង្គការសហប្រជាជាតិ នៅកម្រិតពិភពលោក និងតំបន់

ជាការឆ្លើយតបទៅនឹងបញ្ហាពិភពលោកនៃភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ លោក **បាន គីមូន** អគ្គលេខាធិការអង្គការសហប្រជាជាតិ បានប្រកាសគំនិតផ្តួចផ្តើមស្តីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ (ZHC) នៅក្នុងសន្និសីទ រីយ៉ូ ២០+ ស្តីពីការអភិវឌ្ឍដោយចីរភាព ក្នុងខែមិថុនា ឆ្នាំ២០១២ ដែលនៅទីនោះ លោកបានប្រកាសចក្ខុវិស័យរបស់លោកសម្រាប់អនាគត - **ពិភពលោកមួយដែលចាកផុតពីភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ**។ ចក្ខុវិស័យនេះ មានចុះបញ្ចាំងនៅក្នុងសរសរស្តម្ភទាំងប្រាំនៃ ZHC៖

- ការទទួលបានដោយសមធម៌ (១០០%) នូវស្បៀងអាហារប្រកបដោយសារជាតុចិញ្ចឹមគ្រប់គ្រាន់ និងតាមថ្លៃសមស្រប គ្រប់រដូវក្នុងឆ្នាំនីមួយៗ
- គ្មានករណីក្រិន អត្រាក្រិន(០%) ក្នុងចំណោមកុមារដែលមានអាយុតិចជាង ២ ឆ្នាំ
- ប្រព័ន្ធស្បៀងអាហារទាំងអស់មាននិរន្តរភាព
- ផលិតកម្ម និងប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូចទាំងអស់(១០០%)នឹងមានកំណើន
- គ្មានការបាត់បង់ ឬ ខ្ជះខ្ជាយស្បៀងអាហារ។

**គំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ** បានបង្កើតឡើងដោយផ្អែកលើហេតុផលថា យើងមិនអាចទទួលយកបានឡើយ ក្នុងករណីដែលប្រជាជនរាប់រយ លាននាក់ រងគ្រោះដោយសារភាពអត់ឃ្លាននៅក្នុងពិភពលោកមួយដែលមានភាពសំបូរបែប។ ក្នុងខែមេសា ឆ្នាំ២០១៣ សារស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យត្រូវបានផ្សព្វផ្សាយជាបន្ថែមនៅក្នុងសន្និសីទជាន់ខ្ពស់មួយ**ស្តីពីភាពអត់ឃ្លាន សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ក្នុងទីក្រុងម៉ាឌ្រីដ ប្រទេសអេស្ប៉ាញ។ សន្និសីទនេះ បានអំពាវនាវដល់សហគមន៍អន្តរជាតិ ឲ្យធ្វើការប្តេជ្ញាលុបបំបាត់ប្រកបដោយនិរន្តរភាពនូវភាពអត់ឃ្លាន អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ នៅត្រឹមឆ្នាំ២០២៥ ទន្ទឹមនឹងសង្កត់ធ្ងន់ពីតម្រូវការដើម្បីចាត់ជាអាទិភាពនូវការអភិវឌ្ឍដោយចីរភាព ជាពិសេស ការពង្រឹងផ្តល់សិទ្ធិអំណាចដល់ស្ត្រី។

នៅថ្នាក់តំបន់**គំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ** ត្រូវបានប្រកាសកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ ដោយអគ្គលេខាធិការរងអង្គការសហប្រជាជាតិ និង

ជាលេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP)។ បន្ទាប់មកទៀត អគ្គលេខាធិការរងបានគាំទ្រដល់កិច្ចផ្តួចផ្តើមនានាដើម្បីប្រែក្លាយ ZHC ទៅជាសកម្មភាពជាក់លាក់ដែលមានកាលកំណត់ ឆ្ពោះទៅសម្រេចគោលដៅតំបន់អាស៊ីប៉ាស៊ីហ្វិកគ្មានភាពអត់ឃ្លាននៅត្រឹមឆ្នាំ២០២៥។ ជាជំហានដំបូង ក្រុមការងារប្រចាំតំបន់នៃអង្គការសហប្រជាជាតិខាងផ្នែកភាពក្រីក្រ និងភាពអត់ឃ្លាន ដែលមាន FAO ជាសហប្រធាន និង UNESCAP និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ជាអនុប្រធាន បានរៀបចំ "ក្របខ័ណ្ឌណែនាំថ្នាក់តំបន់សម្រាប់ការសម្រេចគោលដៅតំបន់អាស៊ី និងប៉ាស៊ីហ្វិកគ្មានភាពអត់ឃ្លាន" ដើម្បីណែនាំដល់រដ្ឋជាសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិក្នុងការរៀបចំ និងអនុវត្តសកម្មភាពនានា ដើម្បីបញ្ចប់ភាពអត់ឃ្លាន តាមរយៈការពិគ្រោះយោបល់ និងការសម្របសម្រួលពហុអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ។ បន្ទាប់មក ក្របខ័ណ្ឌណែនាំនេះ ត្រូវបានបង្ហាញជូនដល់មន្ត្រីជាន់ខ្ពស់នៃប្រទេសជាសមាជិកនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកម្រិតតំបន់ និងសមាហរណកម្មនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលកោះប្រជុំដោយ ESCAP នៅក្នុងខែធ្នូ ឆ្នាំ២០១៣។ នៅក្នុងពេលនោះ ប្រទេសជាសមាជិកបានទទួលស្គាល់ពីសារៈសំខាន់នៃ ZHC សម្រាប់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ដើម្បីជួយប្រទេសនានាដែលមានតម្រូវការជាពិសេស ដូចជា ប្រទេសអភិវឌ្ឍន៍តិចតួច ប្រទេសកំពុងអភិវឌ្ឍន៍មិនជាប់សមុទ្រ និងរដ្ឋកំពុងអភិវឌ្ឍន៍នៅលើកូនកោះនានា។

## ១.៤ ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា បានប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (CARD) ជាស្ថាប័នបង្គោលសម្រាប់សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល (CSOs) និងរៀបចំផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ (NAP) នៅត្រឹមឆ្នាំ២០២៥។ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសជាផ្លូវការនូវ***គំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យ*** កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៥ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា និងទីភ្នាក់ងារអង្គការសហប្រជាជាតិដទៃទៀត ដែលរួមមាន FAO, UNICEF, និង WFP ជាដើម។ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួន នឹងពង្រឹងកិច្ចសហការ ដើម្បីកែលម្អសន្តិសុខស្បៀង និងលុបបំបាត់ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ។ ដំណើរការនេះ នឹងរួមបញ្ចូលការវិនិយោគនានា ដើម្បីបង្កើនផលិតភាព និងប្រាក់ចំណូលរបស់កសិករ និងឱកាសការងារសម្រាប់ពលករនៅតាមជនបទក្នុងការរកប្រាក់ចំណូល ដោយផ្តោតជាពិសេសលើស្ត្រី និងយុវជន និងការ

កាត់បន្ថយនូវការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារ។ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ នឹងដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភ ដោយពង្រឹងវិធានការគាំពារសង្គមផងដែរ ដែលរួមទាំងបង្កើនការផ្តល់អាហារនៅតាមសាលារៀន និងកម្មវិធីអាហារូបករណ៍សម្រាប់គ្រួសារក្រីក្រ និងបង្កើនលទ្ធភាពទទួលបានសេវាគាំពារមាតានិងទារក និងលើកកម្ពស់ការប្រើប្រាស់ចំណីអាហារដែលមានសារជាតុចិញ្ចឹមគ្រប់គ្រាន់ ដោយកែប្រែឥរិយាបថ និងទម្លាប់នៃការផ្តល់របបអាហារ និងបង្កើនអនាម័យ និងការរស់នៅស្អាតផងដែរ។ ការយកចិត្តទុកដាក់ក៏បានផ្តោតជាពិសេសផងដែរ លើការចូលរួមយ៉ាងសកម្មរបស់ភ្នាក់ងារក្នុងវិស័យឯកជន តាមវិធីដែលមានអត្ថន័យ ដើម្បីធានាថា ប្រជាពលរដ្ឋទាំងអស់ទទួលបានស្បៀងអាហារតាមថ្លៃសមរម្យ ប្រកបដោយសារជាតុចិញ្ចឹមគ្រប់គ្រាន់ និងសុវត្ថិភាព។ ការយកចិត្តទុកដាក់ក៏ផ្តោតជាពិសេសផងដែរ លើការធានាថា រាល់គំនិតផ្តួចផ្តើមសុទ្ធតែមាននិរន្តរភាពខាងអេកូឡូស៊ី ហិរញ្ញវត្ថុ និងស្ថាប័ន។ កិច្ចប្រឹងប្រែងបំពេញបន្ថែមដើម្បីពង្រឹងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានា ដែលមានលក្ខណៈអំណោយផល នឹងគាំទ្រដល់គំនិតផ្តួចផ្តើមទាំងនេះ។

## ១.៨ ដំណើរការ និងយន្តការស្ថាប័ននៃការរៀបចំផែនការសកម្មភាពជាតិ

ការរៀបចំផែនការសកម្មភាពជាតិ**ស្តីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ**នេះ ផ្អែកលើគោលនយោបាយ និងផែនការយុទ្ធសាស្រ្តដែលមានស្រាប់របស់រដ្ឋាភិបាល និងបំពេញបន្ថែមចំពោះគោលនយោបាយនិងយុទ្ធសាស្រ្តទាំងនោះ ដែលរួមទាំងយុទ្ធសាស្រ្តចតុកោណជំហានទី៣, ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (NSDP២០១៤-២០១៨), យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (NSFSN), យុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា (NSPS) ក៏ដូចជា៖ ផែនការអភិវឌ្ឍន៍តាមវិស័យ ដែលរួមទាំងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម (ASDP), ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនអាហារូបត្ថម្ភក្នុងវិស័យសុខាភិបាល (FTRM) ដើម្បីកែលម្អអាហារូបត្ថម្ភ, និងយុទ្ធសាស្រ្តជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅជនបទ (២០១៤ - ២០១៥)។ ផែនការសកម្មភាពជាតិនេះ ក៏រួមបញ្ចូលផងដែរ នូវសកម្មភាពពាក់ព័ន្ធនានា ដែលទាក់ទងនឹងភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ដែលមានចុះបញ្ចាំងនៅក្នុងគោលនយោបាយ និងផែនការយុទ្ធសាស្រ្តអន្តរវិស័យសំខាន់ៗ ដែលរួមទាំងផែនការនារីរតនៈIV និងផែនការយុទ្ធសាស្រ្តជាតិស្តីពីបម្រែបម្រួលអាកាសធាតុកម្ពុជា ២០១៤ – ២០២៣។ (ឧបសម្ព័ន្ធ ៣ មានតារាងសង្ខេបគោលនយោបាយ និងយុទ្ធសាស្រ្តនានា ដែលផ្តល់ព័ត៌មានសម្រាប់ការរៀបចំផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យ NAP/ZHC)។

ការរៀបចំផែនការសកម្មភាពជាតិ បានធ្វើឡើងទៅតាមការណែនាំរបស់គណៈកម្មការផ្ដល់យោបល់ នៃក្រុមការងារបច្ចេកទេសចម្រុះស្ដីពីការគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (TWG/SP&FSN)។ គណៈកម្មការផ្ដល់យោបល់នេះ មានប្រធាន TWG/SP&FSN និងអ្នកសម្របសម្រួលអង្គការសហប្រជាជាតិនៅកម្ពុជា ធ្វើជាសហប្រធាន។ គណៈកម្មការនេះ បានដឹកនាំការងាររបស់ក្រុមការងារចំពោះកិច្ចពីរដែលបានចាត់តាំងឲ្យរៀបចំសេចក្ដីព្រាងក្នុងសរសរស្ដម្ភទាំងប្រាំនៃផែនការសកម្មភាពជាតិ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បានដឹកនាំការរៀបចំសេចក្ដីព្រាងសម្រាប់សរសរស្ដម្ភ ១, ៣-៥, ចំណែកក្រសួងសុខាភិបាល (MoH) បានដឹកនាំរៀបចំសេចក្ដីព្រាងសរសរស្ដម្ភ ២។ (ឧបសម្ព័ន្ធ ២ បង្ហាញពីលក្ខខណ្ឌប្រតិបត្តិរបស់ក្រុមការងារចំពោះកិច្ចនេះ)។ គណៈកម្មការផ្ដល់យោបល់ ក៏បានកោះប្រជុំពេញអង្គនៃក្រុមការងារ TWG/SP&FSN ផងដែរ ដើម្បីជូនព័ត៌មានអំពីការវិវត្តនៃ NAP/ZHC។ FAO បានផ្ដល់ជំនួយបច្ចេកទេស ដើម្បីគាំទ្រដល់ការរៀបចំ NAP/ZHCនេះ។

# ផ្នែកទី ២ ធាតុសំខាន់ៗនៃផែនការសកម្មភាព

## ២.១ គោលដៅរួមនៃផែនការសកម្មភាពជាតិ

សន្តិសុខស្បៀង និងអាហារូបត្ថម្ភអាចសម្រេចបាន គឺនៅពេលណាដែលភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ត្រូវបានកាត់បន្ថយរហូតដល់កម្រិតដែលនៅសល់មានតិចតួចបំផុត។ សូចនាករនានា គឺជាតម្រូវការសម្រាប់ណែនាំដល់ការវាយតម្លៃវឌ្ឍនភាពជារួម ឆ្ពោះទៅសម្រេចឲ្យបាននូវគោលដៅ **"កម្ពុជាចាកផុតពីភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ នៅត្រឹមឆ្នាំ២០២៥"**។ តារាង ២.១ លើកស្នើសូចនាករមួយចំនួនអំពីវឌ្ឍនភាពជារួមនៅក្នុងអំឡុងពេលនៃការរៀបចំ NAP/ZHC។ សូចនាករដែលទទួលបានការឯកភាពជាចុងក្រោយ នឹងប្រើប្រាស់សម្រាប់វាស់វែងអំពីវឌ្ឍនភាពជារួម សម្រាប់ជាផ្នែកមួយនៃការរៀបចំផែនការអនុវត្តដែលនឹងត្រូវសម្របសម្រួល ដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

| សូចនាករ | លក្ខខណ្ឌគោល ២០១៥ | ចំណុចដៅ ២០១៨ | ចំណុចដៅ ២០២៣ | ចំណុចដៅ ២០២៥ |
|---|---|---|---|---|
| **ប្រេវ៉ាឡង់នៃករណីកង្វះស្បៀងអាហារ និងភាពអត់ឃ្លាន** | | | | |
| សន្ទស្សន៍ភាពអត់ឃ្លានសកល (GHI)[២] | ២២,៦ | | | |
| គ្រួសារដែលខ្វះស្បៀងរយៈពេលមួយខែ ឬច្រើនជាងនេះ | | | | |
| ពិន្ទុអំពីការបរិភោគចំណីអាហារ (FCS): គ្រួសារដែលមានអាហារបរិភោគក្នុងកម្រិតដែលអាចទទួលយកបាន | | | | |
| **អត្រាប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភ** (%) | | | | |
| % កុមារអាយុក្រោម៥ឆ្នាំដែលគ្រិនជាមធ្យម /ធ្ងន់ធ្ងរ (កំពស់ធៀបនឹងអាយុ < 2SD) | ៣២ | ២៥(២០២០) | | ២០ |
| % កុមារអាយុក្រោម៥ឆ្នាំដែលមិនគ្រប់ទម្ងន់កម្រិតមធ្យម/ធ្ងន់ធ្ងរ (ទម្ងន់ធៀបនឹងអាយុ < 2SD) | ២៤ | ១៩ (២០២០) | | ១៤ |

[2] វិទ្យាស្ថានអន្តរជាតិស្រាវជ្រាវគោលនយោបាយស្បៀងអាហារនិងរបាយការណ៍ អភិវឌ្ឍន៍មនុស្សដោយ UNDP

| | | | | |
|---|---|---|---|---|
| % កុមារអាយុក្រោម៥ឆ្នាំ ដែលស្គមស្គាំង (ទម្ងន់ធៀបនឹងកំពស់ < 2SD) | ១០ | ៧(២០២០) | | ៥ |
| % កុមារអាយុក្រោម៥ឆ្នាំដែលមានភាពសញ្ញាស្លេកស្លាំង | ៥៦ | ៥០(២០២០) | | ៤០ |
| កង្វះជីវជាតិអាក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ | ៩ | ៨(២០២០) | | ៧ |
| តម្លៃមេដ្យានជាតិអ៊ីយ៉ូតក្នុងទឹកនោមសម្រាប់ស្ត្រី | ៦៣ | ១៥០(២០២០) | | ១៥០ |
| %ស្ត្រីក្នុងស្គមស្គាំងអាយុពី ១៥-៤៩ ឆ្នាំ (BMI < ១៨.៥ គ.ក្រ/ម៉ែតការ៉េ) | ១៤ | ៧(២០២០) | | ៥ |
| %ស្ត្រីស្លេកស្លាំងក្នុងអាយុ១៥-៤៩ឆ្នាំមានភាពស្លេកស្លាំង | ៤៥ | ៣៥(២០២០) | | ៣០ |
| **សុខភាព** | | | | |
| អត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំ (ក្នុង១ពាន់កំណើតរស់) | ២៨ | រង់ចាំបញ្ជាក់ | | |
| អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ (ក្នុង១ពាន់កំណើតរស់) | ៣៥ | រង់ចាំបញ្ជាក់ | | |
| អត្រាមរណភាពមាតា (ក្នុង១សែន កំណើតរស់) | ១៧០ | ១៣០(២០២០) | | |
| **ភាពក្រីក្រ** | | | | |
| ចំនួនប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ | ១៨,៨(២០១៣) | ១៣,៨ | | |
| អត្រាភាពក្រីក្រនៅជនបទ | ១៩,៧ (២០១៣) | ១៤,៧ | | |
| អត្រាភាពក្រីក្រស្បៀងអាហារ | <៥ | <៥ | | |

## ២.២ វិស័យអាទិភាពនៃផែនការសកម្មភាពជាតិ - សរសរស្តម្ភទាំងប្រាំ

***ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ***នៅកម្ពុជា បែកចេញជាសរសរស្តម្ភយុទ្ធសាស្ត្រចំនួនប្រាំ (ដ្យាក្រាម ២.១)។ សរសរស្តម្ភនីមួយៗ មានលទ្ធផលមួយចំនួនដែលជាប់ពាក់ព័ន្ធនឹងធាតុចេញមួយចំនួន។ ធាតុចេញនីមួយៗ មានជាប់ពាក់ព័ន្ធនឹងអន្តរាគមន៍អាទិភាពមួយចំនួន។ អន្តរាគមន៍ទាំងនេះត្រូវបានបង្ហាញជាសកម្មភាពដែលគួរតែត្រូវបានអនុវត្តដើម្បីសម្រេចគោលដៅដែលមានចែងនៅក្នុងផែនការសកម្មភាពជាតិនេះ។

## ដ្យាក្រាម ២.១ - ធាតុផ្សំជាយុទ្ធសាស្ត្រនៃផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ

### គោលដៅ
កម្ពុជាគ្មានភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ នៅត្រឹមឆ្នាំ ២០២៥

#### សសរស្តម្ភ ១
ការទទួលបានដោយសមធម៌១០០% នូវស្បៀងអាហារប្រកបដោយសារជាតុចិញ្ចឹមគ្រប់គ្រាន់ និងតាមថ្លៃ សមស្រប គ្រប់រដូវក្នុងឆ្នាំនីមួយៗ

**លទ្ធផល ១.១**
ប្រជាពលរដ្ឋក្រីក្រនិងគ្មានទីពឹង អាចទទួលបានស្បៀងអាហារពីប្រភពខុសៗគ្នាជាច្រើន

**លទ្ធផល ១.២**
ផលប៉ះពាល់នៃការប្រែប្រួលថ្លៃស្បៀងត្រូវបានកាត់បន្ថយតាមរយៈទីផ្សារបើកចំហនិងយុត្តិធម៌ និងការអនុវត្តនូវគោលនយោបាយពាណិជ្ជកម្ម នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិបានល្អ

#### សសរស្តម្ភ ២
អត្រាក្រិនក្រិះកុមារ ដែលមានអាយុតិចជាង ២ ឆ្នាំ ទាំងអស់សូន្យ

**លទ្ធផល ២.១**
គ្រួសារកម្ពុជា ជាពិសេសស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ បានទទួលសេវាអាហារូបត្ថម្ភ និងទឹកស្អាតនិងអនាម័យជនបទច្រើនជាងមុន

**លទ្ធផល ២.២**
សេវាវិស័យសុខាភិបាលក្នុងការគាំទ្រដល់អាហារូបត្ថម្ភសម្រាប់កុមារ និងមាតាត្រូវបានពង្រឹង

#### សសរស្តម្ភ ៣
ប្រព័ន្ធស្បៀងអាហារទាំងអស់មាន និរន្តរភាព

**លទ្ធផល ៣.១**
ស្តង់ដារនិរន្តរភាពត្រូវបានបង្កើតសម្រាប់កសិករ, កសិ-អាជីវកម្ម, សហគមន៍, រដ្ឋាភិបាល, សហភាពកសិករ, និងសង្គមស៊ីវិលទាំងអស់

**លទ្ធផល ៣.២**
កសិកម្មដែលមាននិរន្តរភាព និងធន់នឹងអាកាសធាតុត្រូវបានអនុវត្ត

**លទ្ធផល ៣.៣**
ភាពស៊ីសង្វាក់គ្នានៃគោលនយោបាយរវាងវិស័យដែលគ្របដណ្តប់កិច្ចការសន្តិសុខស្បៀង ឧស្សាហកម្ម គោលនយោបាយពាណិជ្ជកម្ម ទេសចរណ៍ ថាមពល ការប្រើប្រាស់ដី ទឹក និងការប្រែប្រួលអាកាសធាតុក្នុងចំណោមវិស័យដទៃទៀត ត្រូវបានធ្វើឲ្យប្រសើរឡើង

#### សសរស្តម្ភ ៤
កំណើន ១០០% នៃផលិតភាព និងប្រាក់ចំណូលរបស់គ្រួសារកសិករតូចតាច

**លទ្ធផល ៤.១**
បានបង្កើនផលិតភាពរបស់កសិករតូចតាច រួមទាំងយុវជន និងស្ត្រី

**លទ្ធផល ៤.២**
ប្រាក់ចំណូលរបស់ផលិតករតូចតាចតាមគ្រួសារ ដែលរួមទាំង ស្ត្រី និងយុវជនត្រូវបានបង្កើនតាមរយៈការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ, ឧស្សាហកម្មក្នុងស្រុក និងកសិ-អេកូទេសចរណ៍

#### សសរស្តម្ភ ៥
គ្មានការបាត់បង់ ឬ ខ្ជះខ្ជាយស្បៀងអាហារ

**លទ្ធផល ៥.១**
ការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារ នៅក្នុងពេលប្រមូលផល ការស្តុកទុក ការដឹកជញ្ជូន ការកែច្នៃ ចែកចាយ និងលក់រាយនិងការបរិភោគ ត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា

**សរសរស្តម្ភ ១** – *ការទទួលបានដោយសមធម៌ ១០០% នូវស្បៀងអាហារប្រកបដោយសារជាតុចិញ្ចឹម គ្រប់គ្រាន់ និងតាមថ្លៃសមស្រប គ្រប់រដូវក្នុងឆ្នាំនីមួយៗ*

សរសរស្តម្ភនេះ ចែងអំពីសកម្មភាពចាំបាច់សម្រាប់បង្កើតបរិយាកាសអំណោយផលដែលធានាថា ពលរដ្ឋទាំងអស់ ជាពិសេសជនក្រីក្រ និងងាយរងគ្រោះបានទទួលនិងអនុវត្តសិទ្ធិរបស់ខ្លួនចំពោះ ស្បៀងអាហារ។ សរសរស្តម្ភនេះ គូសបញ្ជាក់ពីសារៈសំខាន់នៃការបង្កើតក្របខ័ណ្ឌគោលនយោបាយសមស្រប ដើម្បីណែនាំដល់សកម្មភាពនៅក្នុងវិស័យពាក់ព័ន្ធ ដូចជា៖ ផលិតកម្មស្បៀងតាមគ្រួសារ, ធានាកម្មសិទ្ធិដី និងការប្រើប្រាស់ដី និងការប្រើប្រាស់ទឹក ការងារសមរម្យ និងឱកាសក្នុងរបរចិញ្ចឹមជីវិត, ស្បៀងបម្រុងនៅក្នុងគ្រាអាសន្ន, និង សេវាកម្មគាំពារសង្គម។ សរសរស្តម្ភនេះ ក៏បង្ហាញផងដែរ ពីតម្រូវការដើម្បីលើកកម្ពស់ បរិយាកាសទីផ្សារដែលមានស្ថិរភាព ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលថ្លៃអាហារ។ លទ្ធផល ចំនួនពីរត្រូវបានកំណត់ ដើម្បីណែនាំដល់ជម្រើសជាតុចេញ និងសកម្មភាពសម្រាប់សរសរស្តម្ភ ១។

**លទ្ធផល ១.១** – *ប្រជាពលរដ្ឋក្រីក្រ និងគ្មានទីពឹងមានសិទ្ធិទទួលបានស្បៀងអាហារពីប្រភពខុសៗគ្នា*

គ្រួសារកម្ពុជាជាច្រើន ជាពិសេស គ្រួសារក្រីក្រ និងដែលងាយរងគ្រោះ ពុំអាចព្យាករណ៍បាន អំពីការទទួលបានស្បៀងក្នុងថ្លៃសមរម្យ និងដែលមានសារជាតុចិញ្ចឹមគ្រប់គ្រាន់ឡើយ។ ពួកគេខ្វះការ យល់ដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការទទួលបានស្បៀងអាហារ ក៏ដូចជា មូលដ្ឋានផលិតកម្ម និងធនធាន ហិរញ្ញវត្ថុ សម្រាប់ផលិត និងទទួលបានស្បៀងអាហារ។ ការវិនិយោគសាធារណៈ និងឯកជនលើ ការអភិវឌ្ឍ ត្រូវតែគិតគូរអំពីសិទ្ធិទទួលបានស្បៀងអាហារ និងលក្ខខណ្ឌរបបអាហារ របស់គ្រួសារក្រីក្រ និងដែលងាយរងគ្រោះ ជាពិសេសស្ត្រី កុមារ និងអ្នករស់នៅជនបទ។ ប្រការនេះ អាចដោះស្រាយបាន តាមរយៈការអនុវត្តគោលនយោបាយ និងច្បាប់នានា ដើម្បីធានាការលើកកម្ពស់យ៉ាងសកម្មនូវសិទ្ធិទទួល បានទាំងនេះ ដោយបង្កើតការយល់ដឹងអំពីសិទ្ធិរបស់ពលរដ្ឋក្នុងការទទួលបានស្បៀង ការពង្រឹងប្រព័ន្ធ ស្បៀងអាហារដែលមាននិរន្តរភាពតាមប្រពៃណី និងការផ្តល់ឱកាសសម្រាប់ការងារសមរម្យ, កិច្ចគាំពារ សង្គម និងជំនួយសង្គ្រោះបន្ទាន់។ ជាតុចេញចំនួនប្រាំមួយត្រូវបានកំណត់នៅក្រោមលទ្ធផលនេះ។

- លក្ខខណ្ឌអំណោយផលត្រូវបានបង្កើតសម្រាប់ប្រជាពលរដ្ឋទាំងអស់ដើម្បីអនុវត្តសិទ្ធិក្នុងការ ទទួលបានស្បៀងអាហារ
- ប្រព័ន្ធកសិកម្ម និងស្បៀងអាហារដែលមាននិរន្តរភាព រួមទាំង ទំនាក់ទំនងទីផ្សារត្រូវបានធ្វើឲ្យ ប្រសើរឡើង
- កសិករក្រីក្រ និងអសន្តិសុខស្បៀង ត្រូវបានពង្រឹងលទ្ធភាពប្រើប្រាស់ដីធ្លីនិងទឹក ដោយនិរន្តរភាព និងដែលមានការធានា

- ការទទួលបានការងារសមរម្យតាមរយៈកម្មវិធីអភិវឌ្ឍន៍សហគ្រិនភាពជនបទ និងកម្មវិធីនានា ដែលផ្តល់ផលកម្រៃត្រូវបានពង្រឹងសម្រាប់យុវជន និងស្ត្រីក្រីក្រនៅជនបទ
- កិច្ចគាំពារសង្គម សេវាកម្មសង្គម និងបណ្តាញសុវត្ថិភាពសង្គម នៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានលើកកម្ពស់
- ការផលិតស្បៀងក្នុងស្រុកប្រកបដោយនិរន្តរភាពត្រូវបានបង្កើន ដែលរួមទាំងដំណាំស្បៀង ឈើហូបផ្លែ សាកវប្បកម្ម ការចិញ្ចឹមសត្វ និងជលផល តាមរយៈការប្រើប្រាស់នូវប្រភពទឹកទាំងលើដីទាំងក្រោមដីដែលមានគុណភាពល្អ ។

**លទ្ធផល ១.២** –ផលប៉ះពាល់នៃការប្រែប្រួលថ្លៃស្បៀងត្រូវបានកាត់បន្ថយ តាមរយៈទីផ្សារបើកចំហ និងសេរី និងគោលនយោបាយពាណិជ្ជកម្មនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ

គ្រួសារក្រីក្រ និងងាយរងគ្រោះ បានរងការប៉ះពាល់ខុសៗគ្នា ដោយសារការប្រែប្រួលនៃការផ្គត់ផ្គង់ និងថ្លៃស្បៀងអាហារ។ ប្រការសំខាន់ គឺត្រូវចាត់វិធានការដែលមានការសម្របសម្រួល ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលបែបនេះ។ កិច្ចការនេះអាចសម្រេចបាន ដោយការបង្កើនស្បៀងបម្រុងរបស់រាជរដ្ឋាភិបាលដែលមានស្រាប់រួចមកហើយសម្រាប់គ្រាអាសន្ន ការកែលម្អគុណភាព និងការទទួលបានកសិផលដែលកាន់តែទុកចិត្តបាន និងព័ត៌មានអំពីថ្លៃកសិផល និងការចូលរួមយ៉ាងសកម្មនៅក្នុងអង្គការពាណិជ្ជកម្មតំបន់ និងពិភពលោក ដែលពាក់ព័ន្ធនឹងទីផ្សារសម្ភារកសិកម្ម ។ លទ្ធផលនេះ មានធាតុចេញចំនួនបួនដើម្បីណែនាំដល់ការធ្វើអន្តរាគមន៍ ។

- ប្រព័ន្ធព័ត៌មាន និងប្រព័ន្ធតាមដានថ្លៃទំនិញ និងទីផ្សារសមស្រប/គ្រប់គ្រាន់ត្រូវបានបង្កើត និងលើកកម្ពស់
- កម្រិតទុកចិត្តបាននៃទិន្នន័យស្ថិតិកសិកម្មនៅជនបទត្រូវបានពង្រឹង
- ស្តុកស្បៀងអាហារសម្រាប់គ្រាអាសន្នត្រូវបានបង្កើត/រក្សាឱ្យមាន
- កិច្ចសហប្រតិបត្តិការនៅថ្នាក់តំបន់/អនុតំបន់ត្រូវបានពង្រឹង ដើម្បីបង្កើនសន្តិសុខស្បៀង និងទប់ស្កាត់ការប្រែប្រួលថ្លៃស្បៀងខ្លាំងហួសហេតុ

**សសរស្តម្ភ ២** – គ្មានករណីគ្រិន (អត្រាគ្រិន០%) ក្នុងចំណោមកុមារដែលមានអាយុតិចជាង ២ ឆ្នាំ

សសរស្តម្ភនេះ ចែងអំពីសកម្មភាពចាំបាច់ ដើម្បីកាត់បន្ថយយ៉ាងច្រើនមូលហេតុនៃកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារអាយុក្រោម២ឆ្នាំ ដោយយោងជាពិសេសទៅការកាត់បន្ថយករណីគ្រិន។ សសរស្តម្ភ ២ មានគោលដៅកែលម្អអាហារូបត្ថម្ភមាតានិងកុមារ ដោយពង្រឹងការទទួលបានអាហារូបត្ថម្ភប្រសើរជាងមុន និងសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ និងការពង្រឹងសេវាកម្ម

អាហារូបត្ថម្ភក្នុងវិស័យសុខាភិបាលសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុតិចជាង ២ ឆ្នាំ។ សរសរស្តម្ភនេះ មានលទ្ធផលរួមចំនួនពីរ។

**លទ្ធផល ២.១** – *គ្រួសារកម្ពុជា ជាពិសេស ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ បានទទួលសេវាអាហារូបត្ថម្ភនិងសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទប្រសើរជាងមុន*

យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ(NSFSN) មានគោលដៅកែលម្អស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ ដោយកែលម្អលទ្ធភាពរបស់ពួកគេក្នុងការទទួលបានអាហារូបត្ថម្ភ និងសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ។ ការផ្តោតជាសំខាន់គឺលើ "**ឱកាស ១.០០០ ថ្ងៃដំបូង**" នៃជីវិត ពោលគឺចាប់ពីពេលម្តាយមានផ្ទៃពោះ រហូតដល់កុមារកើតបានអាយុ២ឆ្នាំ ជាពេលដែលកង្វះអាហារូបត្ថម្ភកុមារបង្កជាគ្រោះថ្នាក់ខ្ពស់បំផុត ហើយការវិនិយោគក្នុងកំឡុងពេលនេះផ្តល់ផលវិជ្ជមានខ្ពស់បំផុតខាងផ្នែកសង្គម និងសេដ្ឋកិច្ច។ ការវិនិយោគនានា ដើម្បីកែលម្អសេវាអាហារូបត្ថម្ភ និងការអប់រំក៏ដូចជា ការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅជនបទ (WASH) គឺជាអន្តរាគមន៍សំខាន់ជាចាំបាច់ដែលផ្តល់លទ្ធភាពឱ្យជនគ្រប់រូបក្នុងការប្រើប្រាស់ទឹកសម្រាប់បរិភោគគ្រប់គ្រាន់ប្រកបដោយអនាម័យល្អ មានសុវត្ថិភាព និងតម្លៃសមរម្យ។ ការកាត់បន្ថយ ឬ លុបបំបាត់ឧបសគ្គខាងហិរញ្ញវត្ថុក៏មានសារៈសំខាន់ផងដែរ ដែលនេះជារបាំងរារាំងគ្រួសារក្រីក្រពីការទទួលបានសេវាសុខភាព និងចំណីអាហារគ្រប់គ្រាន់សម្រាប់មាតា និងកុមារ។ វិធីសាស្ត្រមួយគឺ ការតភ្ជាប់ឲ្យបានប្រសើរជាងមុននូវយន្តការជំនួយសង្គមកិច្ចសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ ទៅនឹងសេវាកម្មនៃការផ្តល់ចំណីអាហារ។ ការពង្រឹងកម្មវិធីផ្តល់ចំណីអាហារ ក៏ទាមទារឱ្យមានការពង្រឹងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីផងដែរ ដើម្បីការពារសុខុមាលភាព និង របបអាហាររបស់ពួកគេផងដែរ។ កិច្ចការនេះក៏ទាមទារផងដែរ ឲ្យស្ត្រីបង្កើនសមត្ថភាពសង្គម-សេដ្ឋកិច្ចរបស់ខ្លួន ដើម្បីគ្រប់គ្រងធនធានក្នុងគ្រួសារ និងធ្វើការសម្រេចអំពីការបែងចែងចំណីអាហារនៅក្នុងគ្រួសារ និងការចំណាយលើការថែទាំសុខភាពផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ពីតម្រូវការដើម្បីបង្កើតយន្តការនានា ដែលកែលម្អការសម្របសម្រួលរវាងវិស័យពាក់ព័ន្ធនានា និងអ្នកពាក់ព័ន្ធ និងកែលម្អការរៀបចំផែនការ និងការពិនិត្យតាមដាននៅកម្រិតសហគមន៍ឱ្យមានលក្ខណៈចម្រុះជាងមុន។ កម្មវិធីផ្តល់អាហារូបត្ថម្ភដែលផ្អែកលើសហគមន៍ ក៏នឹងត្រូវដាក់ឲ្យអនុវត្តសាកល្បងជាបរិធានមួយដើម្បីពង្រីកសកម្មភាពដែលមានការសម្របសម្រួលនៅថ្នាក់មូលដ្ឋានផងដែរ។ លទ្ធផលនេះ បង្កើតឱ្យមានធាតុចេញចំនួនបួន ដែលណែនាំដល់ការជ្រើសរើសសកម្មភាពពាក់ព័ន្ធ។[3]

---

3 ប្រភព:យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (២០១៤-២០១៨), ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ, ខែមេសា២០១៤

- សេវាកម្ម និងការអប់រំអំពីអាហារូបត្ថម្ភត្រូវបានបង្កើន និងពង្រឹង
- ការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅជនបទ និងការរស់នៅស្អាតត្រូវបានកែលម្អ
- ឧបសគ្គខាងហិរញ្ញវត្ថុសម្រាប់គ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ ត្រូវបានកាត់បន្ថយ
- កម្មវិធីអាហារូបត្ថម្ភដែលផ្អែកលើសហគមន៍ (CBNP) ត្រូវបានអនុវត្ត

**លទ្ធផល ២.២-** *សេវាសុខាភិបាលនិងអាហារូបត្ថម្ភដែលគាំទ្រដល់ការគាំពារមាតា និងទារកត្រូវបានពង្រឹង*

លទ្ធផលនេះ ផ្តោតលើតួនាទីសំខាន់នៃការលម្អសេវាអាហារូបត្ថម្ភក្នុងវិស័យសុខាភិបាល ដែលនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការកែលម្អអាហារូបត្ថម្ភសម្រាប់កុមារអាយុក្រោម២ឆ្នាំ។ ជាលទ្ធផលប្រការនេះ ចែងអំពីកត្តាសំខាន់ៗមួយចំនួនខាងការផ្គត់ផ្គង់សេវាសុខភាព និងអាហារូបត្ថម្ភសម្រាប់មាតា និងកុមារ ដែលរួមទាំង កុមារអាយុក្រោម៥ឆ្នាំផងដែរ។ ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍សំខាន់ៗ បានរៀបចំយុទ្ធសាស្ត្រជាតិស្តីពីអាហារូបត្ថម្ភគ្រប់ជ្រុងជ្រោយ ដើម្បីណែនាំដល់ការអន្តរាគមន៍ជាច្រើន ដែលមានប្រសិទ្ធភាព ចំណាយតិច ដើម្បីកាត់បន្ថយបន្ទុករបស់រដ្ឋាភិបាលទាំងផ្នែកធនធានមនុស្ស សង្គមនិងសេដ្ឋកិច្ច ដែលពាក់ព័ន្ធជាមួយកង្វះអាហារូបត្ថម្ភ។ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រនេះ កម្មវិធីជាតិអាហារូបត្ថម្ភ ដោយមានកិច្ចសហការជិតស្និទ្ធជាមួយនាយកដ្ឋាននានានៃក្រសួងសុខាភិបាល និងស្ថាប័នជាតិដទៃទៀត ព្រមទាំងដៃគូអភិវឌ្ឍន៍នានា បានរៀបចំ "**ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ** ២០១៤-២០២០" (FTRM)។ ផែនទីបង្ហាញផ្លូវនេះ គាំទ្រដល់យុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ ដោយកំណត់អត្តសញ្ញាណអន្តរាគមន៍សំខាន់ៗ ដែលអាចអនុវត្តជាទ្រង់ទ្រាយធំនៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ដើម្បីកាត់បន្ថយបន្ទុកនៃកង្វះអាហារូបត្ថម្ភមកលើជាតិ។[4]

ផែនទីបង្ហាញផ្លូវ FTRM កំណត់គោលបំណង និងយុទ្ធសាស្ត្រទូទៅ ដើម្បីពង្រីកកញ្ចប់ស្នូលមួយនៃអន្តរាគមន៍អាហារូបត្ថម្ភជាក់លាក់ ដែលបានបង្កើនយ៉ាងច្រើននូវសេវាសុខភាព ដើម្បីការពារស្ត្រី និងកុមារ នៅក្នុងអំឡុងពេល ១.០០០ ថ្ងៃដំបូងនៃជីវិតដែលគិតចាប់ពីអំឡុងពេលមានផ្ទៃពោះ ដល់ទារកកើតមកមានអាយុ ២៤ ខែដែលជារយៈពេលងាយរង។ លទ្ធផលនេះផ្សំដោយធាតុចេញចំនួនប្រាំមួយ ដើម្បីកំណត់អត្តសញ្ញាណជម្រើសសកម្មភាពជាក់លាក់។

- ស្ត្រីមានផ្ទៃពោះបានទទួលការប្រឹក្សាអំពីអាហារូបត្ថម្ភ និងការផ្តល់មីក្រូសារជាតិបន្ថែមក្នុងពេលមានផ្ទៃពោះ

---

4 ប្រភព៖ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ ២០១៤-២០២០", ទំព័រ៣ អារម្ភកថា, ភ្នំពេញ, ឧសភា២០១៥

- ការកំណត់អត្តសញ្ញាណ និងការព្យាបាលបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ (SAM) ត្រូវបានកែលម្អ
- ការបន្ថែមមីក្រូសារជាតិសម្រាប់កុមារអាយុក្រោម ៥ ឆ្នាំ ត្រូវបានបង្កើន
- ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ និងការផ្តល់អាហារបន្ថែមត្រូវបានបង្កើន
- វិសាលភាពគ្របដណ្តប់នៃការបញ្ចូលមីក្រូសារជាតិបន្ថែមទៅក្នុងចំណីអាហារត្រូវបានពង្រីក
- ទិន្នន័យអាហារូបត្ថម្ភ និងសេវាកម្មព័ត៌មានត្រូវបានកែលម្អ

## **សរសរស្តម្ភ ៣**– *ប្រព័ន្ធស្បៀងអាហារទាំងអស់មាននិរន្តរភាព*

សរសរស្តម្ភ៣ផ្តោតលើតម្រូវការដើម្បីធានាថាប្រព័ន្ធកសិកម្មនិងការផលិតស្បៀងមាននិរន្តរភាពសង្គម សេដ្ឋកិច្ច និងអេកូឡូស៊ីនៅគ្រប់លំដាប់ថ្នាក់។ សរសរស្តម្ភនេះ ទទួលស្គាល់ថាអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ស្បៀងអាហារ (FSC) មានការយល់ដឹងរួមគ្នាអំពីស្តង់ដារនិរន្តរភាពដែលរួមទាំងវិធានការនានាដែលទាក់ទងនឹងសុវត្ថិភាពចំណីអាហារផងដែរ។ សរសរស្តម្ភនេះ ក៏ទទួលស្គាល់ផងដែរថា វិស័យកសិកម្មកម្ពុជា ដែលរួមទាំងហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូន មានភាពងាយរងគ្រោះជាខ្លាំង នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ភាពងាយរងគ្រោះរបស់កម្ពុជានៅចំពោះមុខការប្រែប្រួលអាកាសធាតុ កាន់តែមានសភាពធ្ងន់ធ្ងរដោយសារបញ្ហានានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេស នៅក្នុងវិស័យព្រៃឈើ ជលផល និងធនធានទឹក។ សរសរស្តម្ភនេះ ក៏ទទួលស្គាល់ផងដែរថា និរន្តរភាពនៃប្រព័ន្ធស្បៀងអាហារ មានលក្ខណៈពហុវិស័យ។ សរសរស្តម្ភ៣ ចែងអំពីបញ្ហានានាដែលទាក់ទងជាមួយការពង្រឹងភាពស៊ីសង្វាក់គ្នានៃគោលនយោបាយរវាងវិស័យនានា ដើម្បីកែលម្អការសម្របសម្រួលនៅក្នុងការរៀបចំផែនការ និងការវិនិយោគក្នុងវិស័យសាធារណៈ និង ឯកជនលើប្រព័ន្ធស្បៀងអាហារដែលមាននិរន្តរភាព។ លទ្ធផលចំនួនបីត្រូវបានកំណត់សម្រាប់ណែនាំដល់ជម្រើសជាតុចេញ និងសកម្មភាពពាក់ព័ន្ធសម្រាប់សរសរស្តម្ភ៣។

### **លទ្ធផល ៣.១** - *ស្តង់ដារនិរន្តរភាពត្រូវបានបង្កើតសម្រាប់កសិករ, កសិ-អាជីវកម្ម, សហគមន៍, រដ្ឋាភិបាល, សហភាព, និងសង្គមស៊ីវិលទាំងអស់*

លទ្ធផលនេះទទួលស្គាល់ថា អ្នកពាក់ព័ន្ធសំខាន់ៗជាច្រើននៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់កសិកម្ម និងស្បៀងអាហារនៅកម្ពុជា រួមមានមន្ត្រីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន មានការយល់ដឹងអំពីទម្លាប់អនុវត្តន៍ប្រកបដោយនិរន្តរភាព ។ ការបង្កើតស្តង់ដាររួមអំពីនិរន្តរភាពនៅទូទាំងប្រព័ន្ធផ្គត់ផ្គង់កសិកម្ម និងស្បៀងអាហារ គឺជាតម្រូវការចាំបាច់ ដើម្បីជួយលើកកម្ពស់និរន្តរភាព

នៃប្រព័ន្ធកសិកម្ម ស្បៀងអាហារ និងអាហារូបត្ថម្ភរបស់កម្ពុជា។ លទ្ធផលនេះក៏ទទួលស្គាល់ផងដែរថា បញ្ហានានាដែលទាក់ទងនឹងគុណភាព និងសុវត្ថិភាពចំណីអាហារ នឹងកាន់តែមានសារៈសំខាន់ នៅក្នុងការឆ្លើយតបនឹងកំណើនប្រាក់ចំណូល និងជម្រើសខុសពីមុនរបស់អ្នកប្រើប្រាស់ផងដែរ។ សុវត្ថិភាពចំណីអាហារ ក៏កាន់តែមានសារៈសំខាន់ផងដែរ នៅពេលកម្ពុជា ផ្តោតលើការបង្កើនការនាំចេញកសិផលរបស់ខ្លួន នៅក្នុងទីផ្សារតំបន់ និងសកលលោក។ លទ្ធផលនេះបានកំណត់ជាតុចេញចំនួនពីរ នៅក្នុងការគាំទ្រដល់សកម្មភាពនានា ដើម្បីបង្កើតនិរន្តរភាព និងស្តង់ដារសុវត្ថិភាពចំណីអាហារ។

- ស្តង់ដារជាតិស្តីពីនិរន្តរភាពផលិតកម្មស្បៀង ត្រូវបានបង្កើតឡើង និងអនុវត្តដោយផលិតករខ្នាតតូចដែលរួមទាំងប្រជាកសិករ និងប្រជានេសាទផងដែរ
- ស្តង់ដារជាតិគុណភាព/សុវត្ថិភាពចំណីអាហារត្រូវបានបង្កើត និងផ្សព្វផ្សាយ

### **លទ្ធផល ៣.២** - *កសិកម្មដែលមាននិរន្តរភាព និងដែលធន់នឹងអាកាសធាតុត្រូវបានអនុវត្ត*

ការអនុវត្តកសិកម្ម និងផលិតកម្មស្បៀង ត្រូវជានាតុល្យភាពរវាងស្ថានភាពអាហារូបត្ថម្ភ និងសន្តិសុខស្បៀង និងនិរន្តរភាពនៃបរិស្ថាន និងធនធានធម្មជាតិ។ ការស្រាវជ្រាវបច្ចុប្បន្ន ត្រូវកំណត់អំពីនិរន្តរភាព និងភាពធន់នឹងអាកាសធាតុនៃការអនុវត្តនៅកម្ពុជា។ បញ្ហានានាដែលទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ មានការពាក់ព័ន្ធជាពិសេសនៅក្នុងបរិបទនៃប្រទេសកម្ពុជា។ នៅអាស៊ី កម្ពុជាគឺជាប្រទេសងាយរងគ្រោះជាងគេទីពីរ បន្ទាប់ពីបង់ក្លាដែស ដោយសារផលប៉ះពាល់នៃព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី ដែលពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ និងសមត្ថភាពរបស់កម្ពុជាក្នុងការគ្រប់គ្រងព្រឹត្តិការណ៍បែបនេះ។ បច្ចុប្បន្ន កម្ពុជាបានជួបរួចមកហើយនូវផលប៉ះពាល់នៃព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី និងគ្រោះមហន្តរាយធម្មជាតិដទៃទៀត ដែលរួមទាំង ព្យុះទីផុងកេតសាណា និងគ្រោះរាំងស្ងួត និងទឹកជំនន់ ដែលពាក់ព័ន្ធជាមួយរបបធាតុអាកាសអែលនីញ៉ូ និងឡានីណា។ ព្រឹត្តិការណ៍បែបនេះ បង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងមកលើផលិតកម្មកសិកម្ម និងប្រាក់ចំណូលរបស់គ្រួសារកសិករតូចតាច ក៏ដូចជា ថ្លៃទំនិញផងដែរ។ កម្ពុជាបានដាក់ឱ្យប្រើប្រាស់រួចមកហើយនូវគោលនយោបាយ និងក្របខ័ណ្ឌស្ថាប័នសម្រាប់ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ លទ្ធផលនេះ បានកំណត់ជាតុចេញចំនួនបីដើម្បីណែនាំដល់ការជ្រើសរើសអន្តរាគមន៍ពាក់ព័ន្ធនានា។

- ពង្រឹងការស្រាវជ្រាវ និងពង្រីកកម្មវិធីផ្សព្វផ្សាយ សម្រាប់ការអនុវត្តដែលមាននិរន្តរភាពនិងដែលធន់នឹងអាកាសធាតុ

- ហេដ្ឋារចនាសម្ព័ន្ធនៅជនបទត្រូវបានពង្រឹង
- ការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះមហន្តរាយត្រូវបានកែលម្អ ដើម្បីពង្រីកភាពធន់របស់គ្រួសារនានាទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

**លទ្ធផល ៣.៣–** *ភាពស៊ីសង្វាក់គ្នានៃគោលនយោបាយរវាងវិស័យនានា ដែលគ្របដណ្តប់កិច្ចការសន្តិសុខស្បៀង ឧស្សាហកម្ម គោលនយោបាយពាណិជ្ជកម្ម ទេសចរណ៍ ថាមពល ការប្រើប្រាស់ដីទឹក និងការប្រែប្រួលអាកាសធាតុក្នុងចំណោមវិស័យដទៃទៀតត្រូវបានជំរុញបន្ត*

ការអភិវឌ្ឍនិងទម្ងាប់នានានៃការផលិតស្បៀងប្រកបដោយនិរន្តរភាព ទាមទារឱ្យមានវិធីសាស្ត្រស៊ីសង្វាក់គ្នា និងមានការសម្របសម្រួលល្អនៅទូទាំងវិស័យ និងស្ថាប័នជាច្រើន ដើម្បីធ្វើសុខដុមនីយកម្មគោលនយោបាយ កម្មវិធីនិងការអនុវត្តអន្តរាគមន៍ពាក់ព័ន្ធនានា។ កម្ពុជាបានបង្កើតរួចមកហើយនូវគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យជាច្រើន ប៉ុន្តែនៅខ្វះធនធានហិរញ្ញវត្ថុ និងស្ថាប័ន ដើម្បីសម្របសម្រួលការវិនិយោគសាធារណៈ និងឯកជន រួមទាំងការវិនិយោគរបស់ដៃគូអភិវឌ្ឍន៍ផងដែរ។ យុទ្ធសាស្ត្រសម្របសម្រួលការអភិវឌ្ឍរបស់កម្ពុជា ២០១៤–២០១៨ ផ្តល់ជាក្របខ័ណ្ឌដ៏សំខាន់សម្រាប់លើកកម្ពស់ការសម្របសម្រួលបែបនេះ ប៉ុន្តែត្រូវការឱ្យមានវិធីសាស្ត្រនានា បន្ថែមទៀតទៅអនាគត ដើម្បីពង្រឹងសកម្មភាពរវាងវិស័យនានា ដែលផ្សារភ្ជាប់វិស័យទាំងនោះ ដូចជា៖ វិស័យកសិកម្ម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ រហូតដល់ការអភិវឌ្ឍជនបទ ការដោះដូរទំនិញ ពាណិជ្ជកម្ម ទេសចរណ៍ ការអភិវឌ្ឍវិស័យឯកជនសម្រាប់សហគ្រាសធុនតូចនិងមធ្យម SMEs, និងការគ្រប់គ្រងធនធានធម្មជាតិ។ ជាតុចេញចំនួនពីរ ត្រូវបានកំណត់ដើម្បីណែនាំដល់ការជ្រើសយកសកម្មភាពពាក់ព័ន្ធ។

- ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាពត្រូវបានកែលម្អ រួមមាន៖ ដីធ្លី ទឹក និងធនធានជលផល និងព្រៃឈើដែលជាសម្បត្តិរួម
- ការសន្ទនាគោលនយោបាយពហុវិស័យ ត្រូវបានពង្រឹង

**សរសរស្តម្ភ ៤** – *កំណើន ១០០ភាគរយនៃផលិតភាព និងប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូច*

កសិកម្មគឺជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា។ ប្រជាជនកម្ពុជាប្រមាណ ៨០ភាគរយរស់នៅតាមទីជនបទ ហើយកសិកម្មផ្តល់ចំណីអាហារសម្រាប់ការបរិភោគប្រចាំថ្ងៃ និងវត្ថុធាតុដើមសម្រាប់ការកែច្នៃក្នុងកសិ-ឧស្សាហកម្ម។ ផលិតកម្មកសិកម្ម និងការនាំចេញ តំណាងឲ្យច្រើនជាង ៣០ភាគរយនៃផលទុនជាតិសរុប GNP។ សារៈសំខាន់នៃវិស័យកសិកម្ម មានឆ្លុះបញ្ចាំងយ៉ាងច្បាស់

នៅក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ NSDPបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជារំពឹងថាកសិកម្ម នឹងបន្តរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈកំណែលម្អសន្តិសុខស្បៀង, ការបង្កើតការងារ, និងការបង្កើនប្រាក់ចំណូលប្រចាំគ្រួសារ។ ជោគជ័យ គួរឲ្យកត់សំគាល់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រក្នុងទសវត្សរ៍កន្លងមកនេះ មួយផ្នែកសម្រេចបានដោយសារការបង្កើនទំហំដីសម្រាប់ដាំដំណាំការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងអត្ថប្រយោជន៍ពីកំណើនយ៉ាងខ្លាំងនៃថ្លៃស្រូវ។ រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថាកំណើនផលិតភាព និងប្រាក់ចំណូលប្រចាំគ្រួសារនៅពេលអនាគត នឹងទាមទារឱ្យមានការបង្កើនប្រពលវប្បកម្មដំណាំស្រូវ និងដំណាំស្បៀងដទៃទៀត ក៏ដូចជាការផ្តោតលើកម្រិតផលចំណេញពីកសិដ្ឋាន បន្ថែមលើប្រាក់ចំណូលពីប្រភពដទៃទៀតផងដែរ។ សរសរស្តម្ភ ៤ ចែងអំពីថាតើផលិតកម្ម និងផលិតភាពនៃស្បៀងដែលមានអាហារូបត្ថម្ភគ្រប់គ្រាន់ពីសំណាក់កសិករខ្នាតតូចអាចកើនឡើងដោយរបៀបណា។ សរសរស្តម្ភនេះ ក៏ទទួលស្គាល់ផងដែរថា កំណើនផលិតភាព និងប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូច មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធផងដែរ។ លទ្ធផលចំនួនពីរណែនាំដល់ជម្រើសជាតុចេញ និងអន្តរាគមន៍។

### **លទ្ធផល ៤.១** – *ផលិតភាពរបស់កសិករខ្នាតតូច ត្រូវបានបង្កើន*

គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ (ASDP) ផ្តល់ក្របខ័ណ្ឌរួមមួយ សម្រាប់បង្កើនទិន្នផល, ការកែលម្អជំនាញបច្ចេកទេសរបស់កសិករ, ពិពិធកម្ម និងការបង្កើនផលចំណេញរបស់កសិដ្ឋានតូចៗ ជាពិសេស កសិករក្រីក្រ។ ASDP ក៏ចាត់ជាអាទិភាពផងដែរ នូវកំណើនផលិតកម្មសត្វ និងត្រី ដែលរួមទាំង វារីវប្បកម្ម និងជលផលសមុទ្រ។ ការបង្កើនប្រពលវប្បកម្ម និងពិពិធកម្មផលិតកម្មកសិកម្ម នឹងត្រូវជំរុញតាមរយៈការបង្កើតនិងការអនុវត្តបច្ចេកវិទ្យាថ្មីៗ តាមរយៈការស្រាវជ្រាវនិងសេវាកម្មផ្សព្វផ្សាយ ក៏ដូចជា ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដែលធន់នឹងអាកាសធាតុ ដែលរួមទាំង ផ្លូវថ្នល់ជនបទ និងប្រព័ន្ធស្រោចស្រពព្រមទាំងប្រព័ន្ធការពារទប់ស្កាត់ទឹកជំនន់-ទឹកប្រៃ កុំឱ្យមានការលិចលង់ ខូចខាតដល់ផលដំណាំដែលបានធ្វើបានផងដែរ។ ផលិតករខ្នាតតូច នឹងពឹងផ្អែកកាន់តែច្រើនឡើងលើអ្នកផ្គត់ផ្គង់សម្ភារៈកសិកម្ម ពីវិស័យឯកជន ដើម្បីទទួលបានធាតុចូលដែលមានគុណភាពខ្ពស់ ដែលរួមទាំងគ្រាប់ពូជ ជីគីមី និងថ្នាំកំចាត់កត្តាចង្រៃ សត្វចិញ្ចឹម និងកូនត្រីពូជ។ ប្រការនេះ ទាមទារឲ្យមានគ្រឹះស្ថានសាធារណៈ ជាពិសេសក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ ក្នុងការដើរតួជានិយ័តករ ដើម្បីធានាថាផលិតករខ្នាតតូចមានលទ្ធភាពទទួលបានធាតុចូលដែលមានគុណភាពល្អ និងក្នុងតម្លៃសមស្រប។

ការកែលម្អការរៀបចំផែនការ និងការសម្របសម្រួលរវាងវិស័យនានានៃការវិនិយោគសាធារណៈ និងវិស័យឯកជន មានសារៈសំខាន់ណាស់ ជាពិសេសក្នុងវិស័យស្រាវជ្រាវ, ការផ្សព្វផ្សាយ, ការស្រោចស្រព, ការដោះទឹកការដឹកជញ្ជូនតាមជនបទ និងអគ្គិសនី។

ធាតុចេញចំនួនប្រាំត្រូវបានកំណត់ ដើម្បីណែនាំការអនុវត្តសកម្មភាពដើម្បីសម្រេចគោលដៅនៃលទ្ធផល៤.១។

- ប្រពលវប្បកម្ម និងពិពិធកម្មប្រព័ន្ធដំណាំរបស់កសិករខ្នាតតូចត្រូវបានបង្កើន និងចំណងទាក់ទង (ធាតុចូល, ធាតុចេញ) ទៅនឹងទីផ្សារត្រូវបានកែលម្អ
- ទម្លាប់អនុវត្តល្អក្នុងផលិតកម្មសត្វ ការបន្តពូជ និងសុខភាពសត្វត្រូវបានកែលម្អ
- ការគ្រប់គ្រងជលផលត្រូវបានកែលម្អ
- សហគមន៍អភិវឌ្ឍន៍កសិកម្ម និងសហគមន៍នេសាទត្រូវបានពង្រឹង
- ការច្នៃប្រឌិតបែបថ្មីក្នុងកសិកម្មត្រូវបានលើកកម្ពស់ តាមរយៈព័ត៌មានវិទ្យា និងការប្រាស្រ័យទាក់ទង

**លទ្ធផល ៤.២** – ប្រាក់ចំណូលរបស់ផលិតករតូចតាចតាមគ្រួសារ ដែលរួមទាំង ស្ត្រី និងយុវជន ត្រូវបានបង្កើន តាមរយៈការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ, ឧស្សាហកម្មក្នុងស្រុក និងកសិ-អេកូទេសចរណ៍

ប្រការសំខាន់ គឺត្រូវបង្កើនប្រាក់ចំណូលរបស់កសិករខ្នាតតូច និងប្រជានេសាទ ដើម្បីពង្រឹងសមត្ថភាពសម្រាប់ផលិតស្បៀងបន្ថែម និងទិញស្បៀងអាហារនៅក្នុងទីផ្សារ។ សហគ្រាសខ្នាតតូច និងមធ្យម (SMEs) បានដើរតួនាទីយ៉ាងសំខាន់រួចមកហើយនៅក្នុងវិស័យកសិកម្មរបស់កម្ពុជា ក្នុងការផ្តល់ការងារ និងប្រាក់ចំណូល។ ការជំរុញ SMEs នៅជនបទ នៅតាមតំបន់ដែលភាពក្រីក្រ និងអសន្តិសុខស្បៀងមានកម្រិតខ្ពស់នឹងដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការងារ និងឱកាសសម្រាប់រកប្រាក់ចំណូល។ ផលិតករកសិកម្មខ្នាតតូច និង SMEs នឹងត្រូវការសេវាកម្មហិរញ្ញវត្ថុក្នុងតម្លៃសមស្រប និងលទ្ធភាពក្នុងការប្រើប្រាស់ទីផ្សារនៅជនបទនិងទីក្រុង និងអ្នកប្រើប្រាស់ងាយស្រួលជាងមុន។ រាជរដ្ឋាភិបាលត្រូវការប្រឹងប្រែងជាបន្ត ដើម្បីបង្កើតឱកាសខាងសេដ្ឋកិច្ចកាន់តែច្រើនជាងមុនសម្រាប់ស្ត្រី ដោយបង្កើនលទ្ធភាព ក្នុងការទទួលបានធនធានសម្រាប់ផលិតកម្ម ដែលរួមទាំង ឥណទាន និងដីធ្លី។ ឧស្សាហកម្មកម្រិតគ្រួសារនៅក្នុងការកែច្នៃកសិផល និងអេកូ/កសិ-ទេសចរណ៍ គឺជាវិស័យពីរដែលអាចផ្តល់ការងារច្រើនបន្ថែមទៀត និងឱកាសក្នុងការរកប្រាក់ចំណូលសម្រាប់គ្រួសារនានានៅជនបទ ជាពិសេស សម្រាប់ស្ត្រី និងយុវជន។ ធាតុចេញចំនួនបួនត្រូវបានកំណត់ដើម្បីណែនាំដល់ការជ្រើសយកសកម្មភាពនានាដែលគាំទ្រដល់លទ្ធផលនេះ។

- លទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប ដូចជា ប្រាក់សន្សំ ឥណទាននិងការធានារ៉ាប់រងសម្រាប់ផលិតករខ្នាតតូច ដែលរួមទាំងស្ត្រី និងយុវជន ត្រូវបានពង្រឹង
- លទ្ធភាពក្នុងការប្រើប្រាស់ទីផ្សារជាតុចូល និងអ្នកប្រើប្រាស់ត្រូវបានពង្រីក
- ឧស្សាហកម្មកម្រិតគ្រួសារត្រូវបានលើកកម្ពស់ តាមរយៈការកែច្នៃកសិផល និងតម្លៃបន្ថែមនៃកសិផលនៅតាមមូលដ្ឋាន ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្រប ជាពិសេសសម្រាប់ស្ត្រី
- អេកូ/កសិ-ទេសចរណ៍ត្រូវបានពង្រឹង និងពង្រីក

## **សសរស្តម្ភ ៥** – *គ្មានការបាត់បង់ ឬ ខ្ជះខ្ជាយស្បៀងអាហារ*

សសរស្តម្ភនេះ គូសបញ្ជាក់ពីតម្រូវការដើម្បីផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយបរិមាណស្បៀងអាហារដែលបាត់បង់ ឬ ខ្ជះខ្ជាយនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ស្បៀងអាហារ។ នៅទីនេះមានការទទួលស្គាល់ថា ការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារបានធ្វើឲ្យថយចុះវត្តមាន, លទ្ធភាពទទួលបាន និងការប្រើប្រាស់ចំណីអាហារដោយសុវត្ថិភាពសម្រាប់ជនកម្ពុជាទាំងអស់ ជាពិសេស អ្នកដែលស្ថិតក្នុងក្រុមមានប្រាក់ចំណូលទាប។ ផ្នែកនេះ ក៏ទទួលស្គាល់ផងដែរថាអ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យសាធារណៈ និងឯកជន មានតួនាទីសំខាន់នៅក្នុងការកាត់បន្ថយការបាត់បង់ និងការខ្ជះខ្ជាយនេះ។ ដូចក្នុងប្រទេសផ្សេងទៀតជាច្រើនផងដែរ នៅកម្ពុជាពុំទាន់មានការសិក្សា និងចងក្រងជាឯកសារបានគ្រប់គ្រាន់អំពីការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារ ក៏ដូចជាសុវត្ថិភាពចំណីអាហារនៅឡើយទេ។ សសរស្តម្ភ ៥ ទទួលស្គាល់ពីតម្រូវការឱ្យមានការយល់ដឹងប្រសើរថែមទៀតអំពីការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារនៅកម្ពុជា ដើម្បីរៀបចំគោលនយោបាយប្រកបដោយប្រសិទ្ធភាព សម្រាប់ណែនាំដល់ការកៀរគរធនធានក្នុងវិស័យសាធារណៈ និងឯកជន និងការសម្របសម្រួលសកម្មភាពនានា។ ផ្នែកនេះ ក៏ទទួលស្គាល់ផងដែរ អំពីតម្រូវការដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងដែលមានស្រាប់ដើម្បីបង្កើនការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ស្បៀងអាហារ។

### **លទ្ធផល ៥.១** – *ការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារ នៅក្នុងពេលប្រមូលផល ការស្តុកទុក ការដឹកជញ្ជូន ការកែច្នៃ ចែកចាយ និងលក់រាយ និងការបរិភោគត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា*

លទ្ធផលនេះ ផ្តោតលើតម្រូវការដើម្បីកាត់បន្ថយការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារនៅតាមខ្សែចង្វាក់ផ្គត់ផ្គង់ស្បៀងអាហារ ដែលរួមទាំងតម្រូវការ ដើម្បីលើកកម្ពស់សុវត្ថិភាពចំណីអាហារផងដែរ។ ការបាត់បង់បែបនេះ ធ្វើឱ្យថយចុះវត្តមានស្បៀងដែលមានសារធាតុចិញ្ចឹមខ្ពស់ និង

ដែលមានសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់នៅកម្ពុជា និងកាត់បន្ថយប្រាក់ចំណូលរបស់ផលិតករតូចតាច។ បញ្ហានានាដែលត្រូវដោះស្រាយរួមមាន តម្រូវការឲ្យមានព័ត៌មានកាន់តែច្រើន និងប្រសើរជាងមុនអំពីការបាត់បង់ និង ការខ្ជះខ្ជាយស្បៀងអាហារនៅតាមខ្សែចង្វាក់ផ្គត់ផ្គង់ទាំងមូល, ការបង្កើនការយល់ដឹងក្នុងចំណោម ផលិតករ និងអ្នកប្រើប្រាស់ អំពីការបាត់បង់ និងការខ្ជះខ្ជាយស្បៀងអាហារ, ការសម្របសម្រួលប្រសើរជាងមុននៅក្នុងវិស័យសាធារណៈនិងឯកជន, ការវិនិយោគលើការអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងក្រោយពេលប្រមូលផលឲ្យកាន់តែមានប្រសិទ្ធផល ដែលរួមទាំងការស្តុកទុក និងការដឹកជញ្ជូន និងគោលការណ៍ណែនាំ និងពង្រឹងការអនុវត្តសុវត្ថិភាពចំណីអាហារផងដែរ។ សកម្មភាពនានាត្រូវបានកំណត់ដើម្បីសម្រេចបានជាតុចេញចំនួនបីដូចតទៅ៖

- អ្នកពាក់ព័ន្ធនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ស្បៀងអាហារ (FSC) មានចំណេះដឹង និងជំនាញបច្ចេកទេសដើម្បីកាត់បន្ថយការបាត់បង់ និងខ្ជះខ្ជាយស្បៀងអាហារ
- ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងស្តុកទុកនៅក្រោយពេលប្រមូលផលត្រូវបានបង្កើន
- អ្នកពាក់ព័ន្ធទាំងអស់ ដែលរួមទាំង ផលិតករ អ្នកលក់រាយ និងអ្នកប្រើប្រាស់ បានប្តេជ្ញាដើម្បីសន្សំសំចៃ និងកាត់បន្ថយការបាត់បង់ស្បៀងអាហារ

## ២.៣ សកម្មភាពអនុវត្ត, ការទទួលខុសត្រូវ និងថ្លៃចំណាយ

ផ្នែកនេះផ្សំដោយសមាសភាគស្នូលនៃផែនការសកម្មភាព សម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា។ តារាង ដ្យាក្រាម២.១ ផ្តល់សេចក្តីសង្ខេបមួយទំព័រអំពីអន្តរាគមន៍ដែលបានស្នើឡើងនៅក្រោមសរសរស្តម្ភនីមួយៗ និងនៅក្រោមលទ្ធផលទាំង ១០នៃNAP/ZHC។ ការងារជាច្រើនដែលត្រូវសម្រេចឱ្យបាន ដើម្បីកំណត់ថ្លៃចំណាយជាក់ស្តែង សម្រាប់អន្តរាគមន៍ជាច្រើនទាំងនេះ។ សេចក្តីពិស្តារនៃសកម្មភាពដែលគ្រោងទុកមានចែងនៅក្នុងតារាងក្នុងឧបសម្ព័ន្ធ១។ តារាងនេះផ្សំដោយតារាងឡុក់ហ្វ្រេម (Log Frame) ចំនួន ១០ ដែលតារាងនីមួយៗ សម្រាប់លទ្ធផលមួយ។ តារាងឡុក់ហ្វ្រេមនីមួយៗផ្តល់សេចក្តីសង្ខេបពិស្តារអំពីលទ្ធផលគ្រោងទុក និងជាតុចេញនានា។ បន្ទាប់មកនៅក្រោមជាតុចេញនីមួយៗ មានចែងអំពីអន្តរាគមន៍ពិស្តារផងដែរ។ ការសម្របសម្រួល និងភាគីទទួលខុសត្រូវលើសកម្មភាពនីមួយៗមានចែងនៅក្នុងជួរឈរ។ នៅមុនតារាងនេះ មានសេចក្តីពន្យល់អំពីចំណុចនានានៅក្រោមជួរឈរនីមួយៗទាំង ១០នៃតារាង។

# ផ្នែកទី ៣ យន្តការសម្របសម្រួល និងអនុវត្ត

## ៣.១ រចនាសម្ព័ន្ធស្ថាប័ន

NAP/ZHC នៅកម្ពុជា មានគោលដៅបង្កើត រចនាសម្ព័ន្ធអភិបាលកិច្ច និងការចាត់ចែងប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព ដោយផ្អែកលើរចនាសម្ព័ន្ធស្ថាប័នដែលមានស្រាប់។ រចនាសម្ព័ន្ធការងារ និងអភិបាលកិច្ចសម្រាប់អនុវត្តផែនការសកម្មភាពនេះ បានផ្អែកលើការរៀបចំស្ថាប័ននៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (TWG/SP&FSN) នៅក្រោមការដឹកនាំរបស់ CARD ស្របតាមគោលការណ៍ណែនាំក្នុងយុទ្ធសាស្ត្រសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCS), ព្រមទាំងយុទ្ធសាស្ត្រដទៃទៀតរបស់រាជរដ្ឋាភិបាល។ ដៃគូអភិវឌ្ឍន៍ នឹងគាំទ្រ CARD ដើម្បីពង្រឹងសមត្ថភាពនៃមុខងារសម្របសម្រួល ដោយផ្តោតជាពិសេសលើការតាមដាននិងវាយតម្លៃ ក៏ដូចជាការកៀរគរធនធានផងដែរ។

កិច្ចការដំបូងមួយសម្រាប់ CARD នៅក្រោយពេលប្រកាសឲ្យអនុវត្ត NAP/ZHC នៅកម្ពុជា គឺការបង្កើតលេខាធិការដ្ឋានបច្ចេកទេសអចិន្ត្រៃយ៍មួយនៅក្នុង TWG/SP&FSN ដើម្បីណែនាំការរៀបចំយន្តការចាត់ចែងសម្រាប់ការសម្របសម្រួល, ការរៀបចំផែនការសកម្មភាពការងារ, ផែនការថវិកា, ការអនុវត្ត, និង ការតាមដាន និងវាយតម្លៃ ដែលនឹងចាប់ផ្តើមក្នុងឆ្នាំ២០១៦។

### ក) តួនាទី និងការទទួលខុសត្រូវ៖ ការសម្របសម្រួល

CARD គឺជាស្ថាប័នសម្របសម្រួល ដែលមានតំណាងមកពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ដែលរួមទាំង ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល/ អង្គការសង្គមស៊ីវិល ដែលធ្វើការលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា។ ឧបនាយករដ្ឋមន្ត្រីមួយរូប គឺជាប្រធាន CARD និងជាប្រធានTWG/SP&FSN។ ប្រធានអង្គការ UNICEF ប្រចាំនៅកម្ពុជា មាននាទីជាអ្នកសម្របសម្រួលដៃគូអភិវឌ្ឍន៍សម្រាប់ការគាំពារសង្គម ហើយនាយកបេសកកម្មប្រចាំប្រទេសអង្គការ USAID ដើរតួជាអ្នកសម្របសម្រួលដៃគូអភិវឌ្ឍន៍សម្រាប់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

ក្នុងឋានៈជាស្ថាប័នអន្តរក្រសួង CARD នឹងដើរតួជាអ្នកសម្របសម្រួលជាន់ខ្ពស់, ការតាមដាន និងរាយការណ៍។ តួនាទីចំបងនៃស្ថាប័ននេះ គឺសម្រួលដល់ការប្រាស្រ័យទាក់ទង និងការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធនានា និងតាមដានវឌ្ឍនភាព ឆ្ពោះទៅសម្រេចគោលបំណងរួមគ្នានៃវិស័យ

សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដូចមានចែងក្នុង NAP/ZHC នៅកម្ពុជា ។ CARD ក៏នឹងសម្រួល និង លើកទឹកចិត្តឲ្យមានការចូលរួមពីវិស័យឯកជន, គ្រឹះស្ថានស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាល/ សង្គមស៊ីវិល ដែលធ្វើការក្នុងវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភផងដែរ។

### ខ) គណៈកម្មការផ្តល់យោបល់ជាន់ខ្ពស់

យន្តការស្ថាប័ន សម្រាប់ផ្តល់យោបល់ដល់NAP/ZHC នៅកម្ពុជា រួមមានថ្នាក់ដឹកនាំជាតិជាន់ខ្ពស់ និងដៃគូអភិវឌ្ឍន៍នៅក្នុងប្រទេស។ ឧបនាយករដ្ឋមន្រ្តី ដែលជាប្រធាន CARD មាននាទីជាប្រធាន គណៈកម្មការផ្តល់យោបល់ជាន់ខ្ពស់ដល់ការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ នៅថ្នាក់ជាតិ ផងដែរ។ អ្នកសម្របសម្រួលអង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជាមាននាទីជាសហប្រធាន។ គណៈកម្មការផ្តល់យោបល់ជាន់ខ្ពស់ នឹងដើរតួជាវេទិកាមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូ អភិវឌ្ឍន៍របស់ខ្លួននៅកម្រិតខ្ពស់បំផុត ដើម្បីទទួលបាន និងចែករំលែកព័ត៌មានអំពីវឌ្ឍនភាពនៃការ អនុវត្ត NAP/ZHC។ គណៈកម្មការនេះ ក៏អាចផ្តល់ការណែនាំ និងគាំទ្រដល់ CARD ទៅតាមករណី សមស្របផងដែរ។ គណៈកម្មការនេះនឹងជួបប្រជុំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ បន្ទាប់ពីកិច្ចប្រជុំ TWG/SP&FSN។ ប្រធាន និងសហប្រធាន ក៏អាចកោះប្រជុំបន្ថែមផងដែរ អាស្រ័យលើភាពចាំបាច់ និងកាលៈទេសៈ។ TWG/SP&FSN នឹងផ្តល់សេវាពីលេខាធិការដ្ឋានដល់គណៈកម្មការផ្តល់យោបល់ ជាន់ខ្ពស់នេះ។ ប្រធាន និងសហប្រធានត្រូវធ្វើការសម្រេចអំពីសមាសភាពនៃគណៈកម្មការនេះ ដែល ភាគច្រើនមកពីក្រសួងស្ថាប័នពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍ដែលជាសមាជិកនៃ TWG/SP&FSN។

### គ) លេខាធិការដ្ឋានបច្ចេកទេសអចិន្ត្រៃយ៍

អង្គភាពសម្របសម្រួលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (FSNCU) នៅក្នុង CARD នឹងមាននាទី ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍។ បន្ថែមលើសេវាគាំទ្ររដ្ឋបាល និងបច្ចេកទេសដល់គណៈកម្មការផ្តល់ យោបល់ជាន់ខ្ពស់ FSNCU នឹងគាំទ្រដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ជាមួយការតស៊ូមតិ និងការកៀរគរធនធាន។ FSNCU ក៏នឹងសម្របសម្រួលរបាយការណ៍អំពីទិន្នន័យ និងព័ត៌មានពីក្រសួង និង ស្ថាប័នពាក់ព័ន្ធនានាផងដែរ ដើម្បីតាមដាន និងវាយតម្លៃវឌ្ឍនភាព ឆ្ពោះទៅសម្រេចគោលបំណង និងគោលដៅដែលបានកំណត់សម្រាប់ការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ ZHC។ FSNCU នឹងផ្តល់យោបល់ជាប្រចាំដល់គណៈកម្មការផ្តល់យោបល់ អំពីតម្រូវការធនធាន និងលើក អនុសាសន៍ដល់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងដើម្បីគាំទ្រដល់ការសម្របសម្រួល ការអនុវត្តអន្តរាគមន៍ ZHC។

### ឃ) ការសម្របសម្រួលថ្នាក់ក្រសួង/ស្ថាប័ន

ក្រសួង/ស្ថាប័ននីមួយៗដែលពាក់ព័ន្ធនៅក្នុងការអនុវត្ត NAP/ZHC ត្រូវបង្ហាញអំពីការចាត់ចែងសម្រាប់ការរៀបចំផែនការ និងការអនុវត្តអន្តរាគមន៍នៅក្នុងវិស័យជាក់លាក់ និងសម្រាប់ការសម្របសម្រួលសកម្មភាពជាមួយភ្នាក់ងារនានានៅក្នុងវិស័យរបស់ខ្លួន។ ក្នុងករណីភាគច្រើន យន្តការបឋមសម្រាប់ការសម្របសម្រួលវិស័យគឺក្រុមការងារបច្ចេកទេសដែលពាកព័ន្ធ។ ក្រសួង/ស្ថាប័ននីមួយៗដែលពាក់ព័ន្ធនៅក្នុងការអនុវត្ត NAP/ZHC ត្រូវរាយការណ៍ជាទៀងទាត់ទៅ CARD។

## ៣.២ ធនធាន

ដើម្បីអនុវត្តបានពេញលេញនូវ NAP/ZHC នៃកម្ពុជា ក្នុងអំឡុងពេលដប់ឆ្នាំ (២០១៦-២០២៥) យើងត្រូវការធនធានយ៉ាងច្រើន។ បន្ថែមលើមូលនិធិដែលបច្ចុប្បន្ននេះផ្តល់ដោយរដ្ឋាភិបាល និងការប្តេជ្ញារបស់ដៃគូអភិវឌ្ឍន៍ NAP/ZHC ទទួលស្គាល់ថា ធនធានថ្មីៗ ក៏នឹងត្រូវការផងដែរ ទើបអាចសម្រេចគោលដៅ និងគោលបំណងនានានៃ NAP/ZHC ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាដោះស្រាយការប្រឈមក្នុងការផ្តល់មូលនិធិក្នុងកម្រិតដែលអាចធ្វើបានជាមួយមូលនិធិផ្ទាល់របស់ខ្លួន និងពុំមានការកាត់បន្ថយការវិនិយោគលើកម្មវិធីអភិវឌ្ឍន៍ក្នុងវិស័យនានានៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភឡើយ។ ទន្ទឹមនឹងតម្រូវការធនធានបន្ថែមពីដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាលក៏នឹងស្វែករកវិធីថ្មីៗដើម្បីលើកកម្ពស់ការចូលរួម និងការវិនិយោគពីវិស័យឯកជនផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការប៉ាន់ស្មានឲ្យបានសុក្រិតអំពីតម្រូវការធនធានពិតប្រាកដនឹងត្រូវធ្វើឡើង ដោយផ្អែកលើការកំណត់ថ្លៃចំណាយពិស្តារនៅក្នុងយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធនានា។ ការងារនេះគឺជាអាទិភាពសំខាន់មួយសម្រាប់ឆ្នាំដំបូងនៃការអនុវត្ត។

- ***ការប្តេជ្ញារបស់រដ្ឋាភិបាលនិងការបន្សុីនូវផលប្រយោជន៍របស់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ***

  រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញារក្សាការយកចិត្តទុកដាក់លើការអភិវឌ្ឍដោយចីរភាព ដោយដោះស្រាយគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDGs); ការប្តេជ្ញាចំពោះយុទ្ធនាការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅលើពិភពលោក; ការប្តេជ្ញាដើម្បីពង្រីកចលនាបង្កើនការអន្តរាគមន៍អាហារូបត្ថម្ភ (SUN); និងកិច្ចសហការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍តាមរយៈក្រុមការងារបច្ចេកទេសនានា, ក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UNDAF), និងកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍នានាសម្រាប់ប្រទេសកម្ពុជា។ ដៃគូអភិវឌ្ឍន៍នានាក៏មានការប្តេជ្ញាខ្ពស់ចំពោះការអនុវត្ត MDGs ផងដែរ និងមានការរំពឹងថា នឹងពង្រីកការប្តេជ្ញាបែបនេះចំពោះ SDGs។ ការប្រកាសគំនិតផ្តួចផ្តើម ZHC នៅកម្រិតពិភពលោកកាលពីឆ្នាំ ២០១២

និងនៅថ្នាក់តំបន់កាលពីឆ្នាំ២០១៣ បង្ហាញនូវការប្តេជ្ញាបែបនេះ និងឆន្ទៈគាំទ្រ និងចូលរួមក្នុងការអនុវត្ត NAP/ZHC នៅកម្ពុជា។

- ***ការអនុមត្ត័ និងការកំណត់ កម្មវិធី និងសកម្មភាពនានា ជាអាទិភាពបន្ថែមទៀត***

  *ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ និងដៃគូអភិវឌ្ឍន៍នានា នឹងអនុមត្ត័ NAP/ZHC នៃកម្ពុជា ហើយឯកភាពថា ការអនុវត្តផែនការសកម្មភាពនេះ នឹងក្លាយជាវិភាគទានដ៏សំខាន់ ដើម្បីរួមចំណែកសម្រេចបានសន្តិសុខស្បៀង និងកាត់បន្ថយយ៉ាងច្រើននូវភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅកម្ពុជា។ ក្រោយការប្រកាសឲ្យអនុវត្ត NAP/ZHC រាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញអន្តរាគមន៍អាទិភាព និងរៀបចំផែនការការងារពិស្តារបន្ថែមទៀត ដោយផ្អែកលើគោលនយោបាយ និងយុទ្ធសាស្ត្រនានាដែលមានស្រាប់។ ដំណើរការនេះ នឹងធ្វើទៅតាមតម្រូវការ ដើម្បីសម្រេចបានអត្រាខ្ពស់បំផុតនៃអត្ថប្រយោជន៍/ថ្លៃចំណាយ និងដើម្បីផ្តល់អត្ថប្រយោជន៍ដល់ក្រុមនានា ដែលមានតម្រូវការខ្ពស់បំផុត។*

- ***ការសម្របសម្រួលលើការតស៊ូមតិ និងការកៀរគរមូលនិធិ***

  *រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានទទួលស្គាល់ជាទូទៅថា បញ្ហានានាដែលទាក់ទងនឹងភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ គឺជាកិច្ចការអន្តរវិស័យ និងគ្មានស្ថាប័នណាតែមួយ ឬ គ្រឹះស្ថានណាមួយតែឯង អាចដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធជាមួយភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភបានឡើយ។ អ្នកពាក់ព័ន្ធទាំងអស់ទទួលស្គាល់ថា ការរៀបចំផែនការ, ការអនុវត្ត, ការតាមដាន និងវាយតម្លៃ ត្រូវតែធ្វើឡើងក្រោមការសម្របសម្រួល ទន្ទឹមនឹងការតស៊ូមតិនិងការកៀរគរមូលនិធិ។ ក្នុងពេលដែលរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ បន្តគាំទ្រដល់សកម្មភាពសម្របសម្រួល ដើម្បីផ្តល់ធនធានហិរញ្ញវត្ថុ និងបច្ចេកទេស ស្របជាមួយការកៀរគរតាមបែបប្រពៃណី រាជរដ្ឋាភិបាលកម្ពុជា ជ្រើសយកការប្រើប្រាស់អភិក្រមដែលផ្អែកលើកម្មវិធី (PBAs) ជាមធ្យោបាយចំបង សម្រាប់រៀបចំផែនការ និងផ្តល់ហិរញ្ញវត្ថុសម្រាប់សកម្មភាពក្រោមការសម្របសម្រួលនានា។ កិច្ចការនេះ អាចរាប់បញ្ចូលការចាត់ចែងតាមបែបថ្មី ដើម្បីសម្រួលឱ្យមានការកៀរគរមូលនិធិរួមគ្នា ដើម្បីផ្តល់ធនធានបន្ថែមដែលនៅខ្វះខាតនៅក្នុងរយៈពេលដប់ឆ្នាំខាងមុខ។ ការចាត់ចែងនានា ដូចជា មូលនិធិហិរញ្ញប្បទានពហុម្ចាស់ជំនួយ និងការគាំទ្រថវិកា អាចផ្តល់ជាយន្តការដ៏មានប្រសិទ្ធភាពផងដែរ សម្រាប់វិភាជន៍មូលនិធិ ទៅតាមទិសដៅរបស់កម្មវិធីនិងគម្រោងនានា ដែលបង្ហាញតម្លាភាពនិងគណនេយ្យភាព ស្របជាមួយអត្រាខ្ពស់នៃផលចំណេញ/ថ្លៃចំណាយ។*

## ៣.៣ កាលវិភាគនៃការអនុវត្ត

ក្រោយការប្រកាសឲ្យអនុវត្ត NAP/ZHC នៅកម្ពុជា ផែនការអនុវត្តពិស្តារមួយនឹងត្រូវរៀបចំឡើង នៅក្រោមការណែនាំរបស់ CARD។ ផ្នែកនេះ កំណត់អំពីគោលការណ៍ណែនាំរួមសម្រាប់ដំណើរការ។ ផ្នែកនេះ ក៏មានបំណងផ្តល់ ព័ត៌មាន និងបង្ហាញពីការរៀបចំផែនការពិស្តារ និងការអនុវត្តសកម្មភាពនានា ដែលធ្វើឡើងស្របតាម កម្មវិធី វដ្តគម្រោង និងការរៀបចំផែនការសកម្មភាពការងារ និងផែនការថវិការបស់ដៃគូអភិវឌ្ឍន៍នៅក្នុងប្រទេសនេះផងដែរ។ តាមតែអាចធ្វើទៅបាន ការរៀបចំផែនការ និងការអនុវត្ត នឹងប្រើប្រាស់អភិក្រម ផ្អែកលើកម្មវិធី (PBAs) ដើម្បីលើកកម្ពស់ការប្រើប្រាស់កាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលនូវធនធាន របស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។

CARD និងអ្នកពាក់ព័ន្ធសំខាន់ៗ ដែលរួមទាំង ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល ក៏ដូចជាដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល នឹងរៀបចំផែនទីបង្ហាញផ្លូវតាមវិស័យ នឹងចាត់អាទិភាព និងកំណត់លំដាប់លំដោយនៃការអនុវត្តសកម្មភាពនានា និងការផ្តល់មូលនិធិដោយផ្អែកលើដំណាក់កាលចំនួនបី៖

- *រយៈពេលខ្លី៖* ការអនុវត្តក្នុងរយៈពេលបីឆ្នាំខាងមុខ (២០១៦ - ២០១៨);
- *រយៈពេលមធ្យម៖* ការអនុវត្តក្នុងរយៈពេលប្រាំបីឆ្នាំខាងមុខ (២០១៦ – ២០២៣);
- *រយពេលវែង៖* ការអនុវត្តសម្រាប់រយៈពេលដប់ឆ្នាំខាងមុខ (២០១៦ – ២០២៥)

វិធីនេះ មានគោលដៅធានាថា អំឡុងពេលនៃការអនុវត្តត្រូវបានបន្ស៊ីជាមួយវដ្តរៀបចំផែនការ NSDP របស់រដ្ឋាភិបាល។ គោលដៅចំពោះមុខ គឺត្រូវកំណត់អត្តសញ្ញាណ និងវិភាជន៍មូលនិធិនានា ដែលដោះស្រាយតម្រូវការចាំបាច់បន្ទាន់ក្នុងរយៈពេលបីឆ្នាំខាងមុខ ដែលជារយៈពេលនៅសេសសល់សម្រាប់អនុវត្តផែនការ NSDP បច្ចុប្បន្ននេះ។ វិធីនេះ សន្មតថា ដំណើរការរៀបចំផែនការថវិការបស់រាជរដ្ឋាភិបាលកម្ពុជា ទាមទារពេលវេលា ចំណែកការផ្តល់ធនធានពីដៃគូអភិវឌ្ឍន៍ច្រើនតែកំណត់សម្រាប់អំឡុងពេលជាក់លាក់។ ទោះបីសកម្មភាពជាក់លាក់ជាច្រើនអាចបានទទួលមូលនិធិគាំទ្រហើយក៏ដោយ ស្របតាមថវិកាបច្ចុប្បន្ន ការកៀរគរធនធានថ្មីៗសម្រាប់សកម្មភាពផ្សេងទៀតនឹងទាមទារពេលបន្ថែមផងដែរ។ សកម្មភាពអាទិភាពទាំងឡាយ ដែលទាមទារនូវការរៀបចំផែនការ និងហិរញ្ញប្បទានសម្រាប់អំឡុងពេលប្រាំបីឆ្នាំខាងមុខ គួរតែបានកំណត់អត្តសញ្ញាណ និងបានរួមបញ្ចូលនៅក្នុងកម្មវិធីរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅក្នុងអំឡុងពេលអនុវត្ត NSDP សម្រាប់ឆ្នាំ ២០១៩ – ២០២៣។ ក្នុងករណីជាច្រើន លទ្ធផលនានា ដែលមាននិរន្តរភាពខាងស្ថាប័ន, ហិរញ្ញវត្ថុ, និងអេកូឡូស៊ី ត្រូវទាមទារនូវការរៀបចំផែនការរយៈពេលវែងជាងនេះ ហើយអំឡុងពេលសម្រាប់

ការផ្តល់ហិរញ្ញវត្ថុនឹងត្រូវមានដល់ដប់ឆ្នាំ ឬ វែងជាងនេះ។ លទ្ធផលបែបនេះ គួរតែបានកំណត់ឱ្យឃើញនៅក្នុងដំណាក់កាលដើមដំបូង ដើម្បីឲ្យការរៀបចំផែនការសមស្របអាចធ្វើទៅបានទាន់ពេលវេលា។

## ផែនការការងារសម្រាប់អំឡុងឆ្នាំ ២០១៦-២០១៨

ផែនការការងារសម្រាប់អំឡុងឆ្នាំ**២០១៦-២០១៨** នឹងផ្តោតលើវិស័យចំនួន ៧ ដែលជាអាទិភាពចំពោះមុខ។ ផែនការការងារឆ្នាំដំបូង ២០១៦ នឹងផ្តោតលើការផ្តួចផ្តើមដំហានសមស្របនានា ដើម្បីដោះស្រាយវិស័យអាទិភាពនីមួយៗ។ វិស័យអាទិភាពទាំងនេះ មានដូចខាងក្រោម៖

- រៀបចំគណនាថ្លៃចំណាយ និងកំណត់ប្រភពមូលនិធិសមស្របសម្រាប់យុទ្ធសាស្ត្រសំខាន់ៗ
- រៀបចំយន្តការតាមដានសម្រាប់យុទ្ធសាស្ត្រសំខាន់ៗ ដោយសង្កត់ធ្ងន់លើការកំណត់រកសូចនាករសមស្រប និងការបង្កើតលក្ខខណ្ឌគោល ដែលជាមូលដ្ឋានសម្រាប់វាស់វឌ្ឍនភាព និងវាយតម្លៃផលប៉ះពាល់
- ធ្វើការស្រាវជ្រាវដើម្បីដោះស្រាយគម្លាតចំណេះដឹងសំខាន់ៗ ដូចជា៖ ការបាត់បង់ និងខ្ជះខ្ជាយស្បៀងអាហារ
- រៀបចំយុទ្ធសាស្ត្រសម្រាប់ឱ្យវិស័យឯកជនបានចូលរួមនៅក្នុងការអនុវត្ត NAP/ZHC
- ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់កិច្ចសហការ និងការសម្របសម្រួលរវាងវិស័យនានា
- បង្កើនកិច្ចប្រឹងប្រែងដើម្បីបង្កើនការយល់ដឹងអំពីបញ្ហានានា ដែលទាក់ទងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ពង្រឹងបរិយាកាសអំណោយផល ដើម្បីធានាការពារសិទ្ធិរបស់ពលរដ្ឋក្នុងការទទួលបានស្បៀងអាហារ

ដូចបានកត់សំគាល់ខាងលើ ផែនការការងារសម្រាប់ឆ្នាំទី១ ក៏រួមបញ្ចូលសកម្មភាពនានារបស់អ្នកពាក់ព័ន្ធផងដែរ ដើម្បីផ្តោតលើការអនុវត្តអន្តរាគមន៍នានាដែលបង្កើតឡើងសម្រាប់ដោះស្រាយបញ្ហាដែលមានការពាក់ព័ន្ធដោយផ្ទាល់ជាមួយភាពក្រិន ដូចមានចែងក្នុងសរសរស្តម្ភ ២។

## ៣.៨ការរាយការណ៍, ការតាមដាន និងការវាយតម្លៃ

អង្គភាពសម្របសម្រួលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (FSNCU) នៅក្រោម TWG/SP&FSN នឹងអនុវត្តប្រព័ន្ធរាយការណ៍, តាមដាន, និងវាយតម្លៃ ដើម្បីផ្តល់ការវាយតម្លៃសមស្រប និងរាយការណ៍អំពីវឌ្ឍនភាព ដោយប្រើប្រាស់ប្រព័ន្ធនានាដែលមានស្រាប់ តាមតែអាចធ្វើបាន។ ក្នុងវិស័យនានាដែលប្រព័ន្ធបែបនេះមិនអាចដំណើរការបាន FSNCU នឹងសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីគាំទ្រឲ្យមានការរៀបចំក្របខ័ណ្ឌសមស្របសម្រាប់រាយការណ៍ ការតាមដាននិងវាយតម្លៃ។

ការតាមដាន និងវាយតម្លៃ (M & E) លើការអនុវត្ត NAP/ZHC នៅកម្ពុជា នឹងធ្វើឡើងនៅលំដាប់ថ្នាក់ខុសៗគ្នា នៃអភិបាលកិច្ច និងរចនាសម្ព័ន្ធអនុវត្តតាមរយៈសរសរស្តម្ភទាំងប្រាំ។ CARD នឹងទទួលខុសត្រូវលើការសម្របសម្រួលក្នុងការរៀបចំ និងអនុវត្តប្រព័ន្ធ M & E រវាងវិស័យនានា នៅកម្រិតពហុវិស័យសម្រាប់ NAP/ZHC។ ប្រព័ន្ធ M & E នឹងយោងទៅសូចនាករសំខាន់ៗដែលមានសង្គតិភាពជាមួយសូចនាករនានា ដែលមានចែងរួចមក ហើយនៅក្នុង NSDP ២០១៤-២០១៨, សូចនាករតាមដានរួមគ្នា(JMIs) របស់ TWG និងផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យជាក់លាក់។

ផែនការ NAP/ZHC កំណត់សូចនាករមូលដ្ឋានគ្រឹះនៅក្នុងវិស័យនានាដែលអាចធ្វើបាន។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានបញ្ជាក់ខាងលើ នៅក្នុងវិស័យជាច្រើន ការបង្កើតសូចនាករបឋមគឺជាតម្រូវការចាំបាច់។ នៅក្នុងអំឡុងពេលចាប់ផ្តើមអនុវត្ត ប្រភេទ, ចំនួន និងកម្រិតនៃការអង្កេតថ្មីៗមួយចំនួន ដែលចាំបាច់សម្រាប់បំពេញភាពខ្វះខាតទិន្នន័យ ដែលមិនរកបាននៅក្នុងការអង្កេតដែលមានស្រាប់ នឹងត្រូវកំណត់ផងដែរ។ ក្នុងន័យនេះ គោលដៅគឺផ្អែកលើការអង្កេត, ប្រព័ន្ធព័ត៌មាន និងស្ថាប័នដែលមានស្រាប់។ ប្រការនេះ រាប់បញ្ចូលការដាក់បញ្ចូលប៉ារ៉ាម៉ែត្រនានាដែលនៅខ្វះទៅក្នុងការអង្កេត, ប្រព័ន្ធ និងដំណើរការព័ត៌មានដទៃទៀតដែលមានស្រាប់។

នៅពីលើនៃប្រព័ន្ធ M & E កិច្ចប្រជុំប្រចាំឆ្នាំនៅថ្នាក់ជាតិនៃអ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្ត NAP/ZHC នៅកម្ពុជា នឹងត្រូវកោះប្រជុំដោយ CARD។ ការប្រជុំនឹងផ្តោតលើ៖

ក) ការវាយតម្លៃសមិទ្ធផលនៃគោលដៅរួមដែលមានចែងក្នុងតារាង ២.១ (សូចនាករគោលដៅរួម), ក៏ដូចជាលទ្ធផល និងធាតុចេញនៃសរសរស្តម្ភនីមួយៗ

ខ) ការវាយតម្លៃលើការអនុវត្ត NAP/ZHC ដែលរួមទាំងវិភាគទានទៅក្នុងសមិទ្ធផលនៃផែនការអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជា នៅតាមវិស័យផងដែរ

គ) ការកំណត់អត្តសញ្ញាណតម្រូវការកម្មវិធីដែលកំពុងអនុវត្ត ដែលរួមទាំងភាពខ្វះចន្លោះនៃវិសាលភាពគ្របដណ្តប់ និងការកៀរគរធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស

ឃ) ការលើកអនុសាសន៍ដែលទាក់ទងនឹងការប្រែប្រួល និងការកែលម្អនៅក្នុងការរៀបចំផែនការ និងក្នុងការអនុវត្តសកម្មភាពនានា ដើម្បីពង្រីកជាបន្ថែមនូវសមិទ្ធផលនៃគោលដៅដែលបានពង្រីកលទ្ធផល និងធាតុចេញ។

# ផ្នែកទី៤ សេចក្តីសន្និដ្ឋាន

NAP/ZHC នៅកម្ពុជា បានឆ្លុះបញ្ចាំងអំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដើម្បី "**បញ្ចប់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀង កែលម្អអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព**" ។ ចក្ខុវិស័យនៃគំនិតផ្តួចផ្តើមស្តីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនេះ បានឆ្លុះបញ្ចាំងនៅក្នុងសរសរស្តម្ភទាំងប្រាំ ដែលត្រូវបានគាំទ្រយ៉ាងទូលំទូលាយលើសកម្មភាពជាក់លាក់នានាដូចជា៖

- ការទទួលបានស្បៀងអាហារគ្រប់គ្រាន់ ១០០% ពេញមួយឆ្នាំ
- គ្មានករណីក្រិនចំពោះកុមារមានអាយុក្រោម២ឆ្នាំ
- ប្រព័ន្ធស្បៀងអាហារទាំងអស់មាននិរន្តរភាព
- ផលិតកម្ម និង ប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូចមានកំណើន១០០%
- គ្មានការបាត់បង់ ឬ ខ្ជះខ្ជាយស្បៀងអាហារ។

NAP/ZHC នៅកម្ពុជា បានផ្តល់ជាផែនទីបង្ហាញផ្លូវពេញលេញនិងចម្រុះមួយដើម្បីសម្រេចគោលដៅខាងលើ ដោយកាត់បន្ថយភាពអត់ឃ្លាននិងកង្វះអាហារូបត្ថម្ភនៅត្រឹមឆ្នាំ២០២៥។ ផែនការសកម្មភាពជាតិ ត្រូវបានតម្រឹមយ៉ាងពេញលេញជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ និងបំពេញបន្ថែមទៅលើគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យនិងអន្តរៈវិស័យផ្សេងៗទៀត ដែលមានស្រាប់។ CARD ត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ចជាស្ថាប័នសម្របសម្រួលរៀបចំផែនការសកម្មភាពនេះ ហើយការអនុវត្តជាភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធនានា។ CARD នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍និងសង្គមស៊ីវិល ដើម្បីកៀរគរឲ្យបានធនធានហិរញ្ញវត្ថុអនុវត្តផែនការសកម្មភាពជាតិ។ CARD ក៏ទទួលស្គាល់ផងដែរ ពីតួនាទីដ៏សំខាន់របស់វិស័យឯកជននៅក្នុងការលុបបំបាត់ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា ហើយ CARD ក៏នឹងដើរតួនាទីជាអ្នកសម្របសម្រួលជាមួយវិស័យឯកជន ផងដែរ។

យើងមានភារកិច្ចសំខាន់ៗជាច្រើនដែលត្រូវតែដោះស្រាយក្នុងអំឡុងពេលដំបូងនៃដំណើរការអនុវត្តផែនការសកម្មភាពជាតិនេះ។ ចំណុចសំខាន់បំផុតនោះ គឺគ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីធានាឱ្យបាននូវការវិនិយោគប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុង

